មាតិកា


វិញ្ញាសាគីមីទី ៣១ ........ ១
ដំណោះស្រាយវិញ្ញាសាគីមីវិទ្យា ៣១ ........ ៣
វិញ្ញាសាគីមីទី ៣២ ........ ២៤
ដំណោះស្រាយវិញ្ញាសាគីមីវិទ្យាទី ៣២ ........ ២៦
វិញ្ញាសាគីមីទី ៣៣ ........ ៣៦
ដំណោះស្រាយវិញ្ញាសាគីមីវិទ្យា ........ ៣៨
វិញ្ញាសាគីមីទី ៣៤ ........ ៥៥
ដំណោះស្រាយប្រធានវិញ្ញាសាគីមីវិទ្យាទី៣៤ ........ ៥៧
វិញ្ញាសាគីមីទី ៣៥ ........ ៧២
វិញ្ញាសាគីមីទី ៣៦ ........ ១២៤
ដំណោះស្រាយវិញ្ញាសាគីមីវិទ្យា៣៦ ........ ១២៦
វិញ្ញាសាគីមីទី៣៧ ........ ១៧៩
ដំណោះស្រាយវិញ្ញាសាគីមីវិទ្យា៣៧ ........ ១៨០


**Please scan QR Code to upload the file**

# អារម្ភកថា

សៀវភៅវិញ្ញាសាគីមីវិទ្យាត្រៀមប្រលងចូលវិទ្យាស្ថានជាតិអប់រំ គ្រូកម្រិតឧត្តម (បរិញ្ញា+១) នេះ ដែលលោកអ្នកកំពុងតែកាន់អាននៅពេលនេះ ត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ជាទីបំផុតក្នុង គោលបំណងផ្តល់ជាឯកសារស្រាវជ្រាវដល់និស្សិត ដែលមានបំណងចង់ប្រលចូលវិទ្យាស្ថានជាតិអប់រំ គ្រូកម្រិតឧត្តម សម្រាប់ត្រៀមប្រលងយកអាហារូបករណ៍ទៅសិក្សាបរទេស និងប្រលងចូលគ្រឹះស្ថាន ឧត្តមសិក្សានានាក្នុងប្រទេស។

លំហាត់ក្នុងវិញ្ញាសានីមួយៗត្រូវបានជ្រើសរើស និង ដកស្រង់ពីឯកសារខ្មែរ និង សៀវភៅ

បរទេសស្របតាមស្តង់ដាអន្តរជាតិ ដែលធ្វើឲ្យអ្នកស្រាវជ្រាវចំនេញពេលវាលាច្រើនក្នុងការអភិវឌ្ឍ

ចំនេះដឹងខ្លួនឯង។

ទោះបីជាមានការប្រុងប្រយ័ត្នចំពោះការសរសេរនិងការបកប្រែសម្រួលជាភាសាខ្មែរយ៉ាងណា ក៏ដោយ ក៏មិនអាចជៀសផុតពីការឆ្គាំឆ្គងឡើយ។ ខ្ញុំបាទសង្ឃឹម លោកគ្រូ អ្នកគ្រូ និស្សិត មិត្តអ្នកអាន គ្រប់មជ្ឈដ្ឋាននឹងជួយផ្តល់មតិ យោបល់ជួយទិតៀនរិះគន់ស្ថាបនា ចំពោះកង្វះខាត និងកំហុសឆ្គង ដែលអាចកើតមានឡើងទាំងផ្នែកការបកប្រែ និងផ្នែកខ្លឹមសារមេរៀន ដើម្បីជួយកែលម្អសៀវភៅនេះ ឲ្យកាន់តែប្រសើរឡើងថែមទៀត។

ជាទីបញ្ចប់ខ្ញុំបាទសូមជូនពរចំពោះលោកអ្នក សូមឲ្យមានសុខភាពល្អ មានប្រាជ្ញាឈ្លាសវៃ និង ទទួលបានជោគជ័យគ្រប់ភារកិច្ច។

ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៩

**ហួន គីមស្រ៊ា**

**Tel: 098 472 472**

**Email: hounkimsrea@gmail.com**

# ឯកសារពិគ្រោះ


- សៀវភៅវិទ្យាសាស្ត្រគីមីវិទ្យាថ្នាក់ទី១២ នៃក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ បោះពុម្ពលើកទី១។
- **Ahmet ARIK, Rahim POLAT, Nasuh, ULKER. Chemistry Grade 11**
- **David E. Goldberg, Ph.D. Schaum's 3000 solved problems in Chemistry, McGraw-Hill Book Company. International Editions 1989**
- **R. S. Boikess Rutgers, C. H. Sorum, How to Solve General Chemistry Problems, 7th Edition, 1987.**
- **Raymond Chang, Brandon Chruickshank. Chemistry 8th edition 2005**
- **Henry F. Holtzolaw, Jr. William R. Robinson 8th edition 1984**
- **Kennethw. Whitten, Raymond E. Davis, Ml Larry Peck. General Chemistry with Qualitative Analysis, 5th edition 1996**
- **John C. Kotz, Paul M. Treichel, Jr. Patrick A. Harman, 5th edition 2003**
- **R.Thomas Myers, ph.D., Keith B. Oldham, D.sc. Salvatore Tocci, A Hartcourt Education Company 2006**
- **Mc Murry Fay, 4th edition**
- **Stanleyr. Radel, Marjorieh. Navidi. West Publishing Company 2nd edition 1994**
- **Silberberg, Chemistry The Molecular Nature of Matter and Change, 5th edition. Mc Graw-Hill Company 2009**
- **Stevens. Zumdahl, Susan A. Zumdahl, 6th edition, Houghton Mifflin Company, 2003**
- **Wayne Tikkanen, John Olmested III, 2nd edition, Wm.C.Brown Publishers, 1997**
- **James.E.Brandy, John R. Holum, Chemistry, The Study of Matter and Its Changes. 1993**
- **Catherine E. Housecraft, Edwin C. Constable, Chemistry An Introduction to Organic, Inorganic and Physical Chemist 2nd edition, Pearson Education 2002**
- **Amos Turk, Herbert Meislich, Frank Brescia, John Arents, Introduction to Chemistry, 1968**

# សៀវភៅវិញ្ញាសាគីមីវិទ្យាត្រៀមប្រលងចូលវិទ្យាស្ថានជាតិអប់រំ គ្រូកម្រិតឧត្តម (បរិញ្ញា+១)




សៀវភៅនេះត្រូវបានរៀបរៀង និងចងក្រងដោយ ហួន គឹមស្រ៊ា


គ្មានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានចំលងឡើងវិញ ទោះជាក្នុងមធ្យោបាយណាក៏ដោយឡើង

**No part of this book may be reproduced in any ways**

## ABBREVIATIONS AND SYMBOLS

| | | | | | |
|---|---|---|---|---|---|
| Amount of substance | n | Equilibrium constant | K | Milli- prefix | m |
| Ampere | A | Faraday constant | F | Molal | m |
| Atmosphere | atm | Formula molar mass | M | Molar | M |
| Atomic molar mass | u | Free energy | G | Mole | mol |
| Avogadro constant | $N_A$ | Frequency | v | Planck's constant | h |
| Celsius temperature | °C | Gas constant | R | Pressure | P |
| Coulomb | C | Gram | g | Rate constant | k |
| Electromotive Force | E | Hour | h | Second | s |
| Energy of activation | Ea | Joule | J | Speed of light | c |
| Enthalpy | H | Kelvin | K | Temperature, K | T |
| Entropy | S | Kilo- prefix | k | Time | t |
| Measure of pressure | mmHg | Liter | L | Volt | V |
| | | | | Volume | V |

| CONSTANTS | Useful Conversion Factors and Relationship |
|---|---|
| $R = 8.314\ J.mol^{-1}.K^{-1}$ | 1 lb = 453.6 |
| $R = 0.0821\ L.atm.mol^{-1}.K^{-1}$ | 1 in 1.54 cm (exactly) |
| $1\ F = 96500\ C.mol^{-1}$ | 1 mi = 1.609 km |
| $1\ F = 96,500\ J.V^{-1}.mol^{-1}$ | 1 km = 0.6215 mi |
| $N_A = 6.022 \times 10^{-34}\ J.s$ | $1\ pm = 1 \times 10^{-12}\ m = 1 \times 10^{-10}\ cm$ |
| $c = 2.998 \times 10^{8}\ m.s^{-1}$ | $1\ atm = 760\ mmHg = 760\ atm = 101,325\ N/m^2$ |
| Proton mass $1.672623 \times 10^{-24}$ g | =101,325 Pa |
| Neutron mass $1.674928 \times 10^{-24}$ g | 1 cal = 4.184 J (exactly) |
| Electron mass $9.109387 \times 10^{-28}$ g | 1 L atm = 101.325 J |
| | 1 J = 1 C x 1 V |

## លក្ខណៈឡូការីត និងអ៊ិចស្ប៉ូណង់ស្យែល Logarithm and Exponent

| Logarithm | Exponent |
|---|---|
| $\log 1 = 0$ | $10^0 = 1$ |
| $\log 10 = 1$ | $10^1 = 10$ |
| $\log 100 = 2$ | $10^2 = 100$ |
| $\log 10^{-1} = -1$ | $10^{-1} = 0.1$ |
| $\log 10^{-2} = -2$ | $10^{-2} = 0.01$ |
| $\log 10^{-3} = -3$ | $10^{-3} = 0.001$ |

| | |
|---|---|
| $\log AB = \log A + \log B$ | $10^A \times 10^B = 10^{A+B}$ |
| $\log \frac{A}{B} = \log A - \log B$ | $(10^n)^m = 10^{n \times m}$ |
| $\log A^n = n \log A$ | $10^A / 10^B = 10^{A-B}$ |

**Natural Logarithms**

**Logarithms taken to base e instead of 10 are known as natural logarithms (denoted by ln or $\log_e$; e is qual to 2.7183. The relationship between common logarithms and natural logarithms is as follows:**

$$\log 10 = 1 \qquad 10^1 = 10$$

$$\ln 10 = 2.303 \qquad e^{2.303} = 10$$

**Thus $\ln æ = 2.303 \log æ$**

**Sometimes we may be given the natural logarithm and asked to find the number it represents. For example**

$$\ln æ = 59.7 \qquad \text{thus } æ = e^{59.7} = 8 \times 10^{25}$$

# សមីការដឺក្រេទី២ The Quadratic Equation

**A quadratic equation takes the from**

**a æ$^2$ + bæ + C = 0**

**If coefficients a, b, and c are known, then æ is given by**

$$\mathbf{x = \frac{-b \pm \sqrt{b^2 - 4ac}}{2a}}$$

**Suppose we have the following quadratic equation:**

**2 æ$^2$ + 5 æ – 12 = 0**

**Solving for æ, we write**

$$\mathbf{x = \frac{-5 \pm \sqrt{(5)^2 - 4(2)(-12)}}{2 \times 2}}$$

**Therefore**

**æ = $\frac{-5+11}{4} = \frac{3}{2}$ and æ = $\frac{-5-11}{4}$ = -4**

**សូមអរគុណ!**

**សូមរង់ចាំអានភាគបន្ត**

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី............

វិញ្ញាសា គីមីទី ៣១

រៀបរៀង ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០១៧

**វិញ្ញាសា៖ ឯកទេសទី១ គីមីវិទ្យា រយៈពេល ៣ ម៉ោង**

ឈ្មោះ.................................លេខបន្ទប់...............លេខតុ................ហត្ថលេខា.................

(សម្រាប់និស្សិតគីមីត្រៀមប្រលង NIE) Tel: 098 472 472

## ប្រធានវិញ្ញាសាគីមីវិទ្យាទី ៣១

១. ក. ចូរកំណត់ចំនួនអេឡិចត្រុងអតិបរិមាដែលមានក្នុងស្រទាប់រងនីមួយៗ 3s, 3d, 4p, 4f, 5f និង 6d។

ខ. ចូរកំណត់ចំនួនអេឡិចត្រុងសរុបក្នុងស្រទាប់រង:

១. អាតូម N (Z = 7) ស្រទាប់រង p ២. អាតូម Si (Z = 14) ស្រទាប់រង s

៣. អាតូម S (Z = 16) ស្រទាប់ d ៤. អ៊ីយ៉ុង $Cl^-$ (Z = 17) ស្រទាប់រង p

តើអាតូម និង អ៊ីយ៉ុងណាខ្លះខាងលើ ជាប៉ារ៉ាម៉ាញ៉េទិច និង ដ្យាម៉ាញ៉េទិច។

គ. តើក្រុមប្រភេទគីមីខាងក្រោមណាខ្លះជាអ៊ីសូអេឡិចត្រូនិចនឹងគ្នា: $Be^{2+}$ (Z = 4), $F^-$ (Z = 9), $Fe^{2+}$ (Z = 26), $N^{3-}$ (Z = 7), He (Z = 2), $S^{2-}$ (Z = 16), $Co^{3+}$ (Z = 27) និង Ar (Z = 18)។

២. ក. សមាសធាតុមួយបានបំបែកនៅសីតុណ្ហភាពជាក់លាក់មួយតាមប្រតិកម្មលំដាប់មួយនៅរយៈពេល 6 ម៉ោងក្រោយមក សមាសធាតុនោះបាននៅសល់ 20%។ គណនាថេរល្បឿន រយៈពេលពាក់កណ្តាលប្រតិកម្ម និង រយៈពេលដែលត្រូវការដើម្បីបំបែកសមាសធាតុនេះឲ្យអស់ 20%។

ខ. សមាសធាតុ A មួយបានបំបែកនៅសីតុណ្ហភាពជាក់លាក់មួយ រយៈពេល 100 s ក្រោយមកសមាសធាតុនោះ បាននៅសល់ 50 %។ តើសមាសធាតុនេះនៅសល់ប៉ុន្មាន បន្ទាប់ពីប្រតិកម្មបំបែកអស់រយៈពេល 200 s បើវាជាប្រតិកម្មលំដាប់១?

គ. ប្រតិកម្មបំបែកស៊ុលផួរីលក្លរ ($SO_2Cl_2$) ទៅជាស្ពាន់ធ័រឌីអុកស៊ីត និង ឧស្ម័នក្លរ គឺជាប្រតិកម្មលំដាប់១ ដែលមានរយៈពេលពាក់កណ្តាលប្រតិកម្មស្មើ 9 នាទី។

១. ចូរសរសេរសមីការនៃប្រតិកម្មបំបែកស៊ុលផួរីលក្លរ ទៅជាស្ពាន់ធ័រឌីអុកស៊ីត និង ឧស្ម័នក្លរ

២. គណនាតម្លៃថេរល្បឿននៃប្រតិកម្មនេះ

៣. គណនាកំហាប់ស៊ុលផួរីលក្លរ ដែលនៅសល់ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តទៅអស់រយៈពេល 10 នាទី បើកំហាប់ដើមរបស់ស៊ុលផួរីលក្លរស្មើនឹង 0.65 M។

៤. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីឲ្យស៊ុលផួរីលក្លរសល់ 4 %?

(គេឲ្យៈ $\ln 0.65 = -0.431$; $\ln 2 = 0.693$; $\ln 5 = 1.609$; $e^{-1.201} = 0.301$)

៣. ចូរថ្លឹងសមីការខាងក្រោមនេះឲ្យបានត្រឹមត្រូវៈ

ក. $Zn + As_2O_3 + H_2SO_4 \rightarrow AsH_3 + ZnSO_4 + H_2O$

ខ. $FeC_2O_4 + KMnO_4 + H_2SO_4 \rightarrow Fe_2(SO_4)_3 + CO_2 + MnSO_4 + K_2SO_4 + H_2O$

គ. $Sb_2S_3 + Na_2CO_3 + C \rightarrow Sb + Na_2S + CO$ (មជ្ឈដ្ឋានអាស៊ីត)

ឃ. $XO_2^+ + YO^+ \rightarrow X_2O_4^{3-} + Y^- + Y_3O_7^{2-}$ (មជ្ឈដ្ឋានបាស)

ង. $Cu_3P + Cr_2O_7^{2-} \rightarrow Cu^{2+} + H_3PO_4 + Cr^{3+}$ (មជ្ឈដ្ឋានអាស៊ីត HCl សណ្ឋានជាម៉ូលេគុល)

ច. $CuSCN + KIO_3 + HCl \rightarrow CuSO_4 + KCl + HCN + ICl + H_2O$

៤. ភាគសំណាកក្រាភីត 5.72 g ត្រូវបានដុតកម្តៅជាមួយ 68.4 g $O_2$ ក្នុងបាឡុងមួយចំណុះ 8.00 L។ សមីការប្រតិកម្មប្រព្រឹត្តទៅដូចតទៅ $C\ (graphite) + O_2\ (g) \longrightarrow CO_2\ (g)$ ។

ក្រោយពីប្រតិកម្មចប់សីតុណ្ហភាពក្នុងបាឡុងគឺ 182 °C។ ចូរគណនាសម្ពាធសរុបក្នុងបាឡុងនេះ

៥. ភាគសំណាកសំលោហៈ Cu-Zn 6.11 g ប្រតិកម្មជាមួយអាស៊ីតក្លរីឌ្រិចបង្កើតឧស្ម័នអ៊ីដ្រូសែន។ បើឧស្ម័នអ៊ីដ្រូសែនដែលទទួលបានមានមាឌ 1.26 L នៅសីតុណ្ហភាព 22 °C និងសម្ពាធ 728 mmHg។ ចូរគណនាភាគរយស័ង្កសីក្នុងសំលោហៈនេះ។ គេឲ្យម៉ាសអាតូមិចៈ Zn : 65.3, Cu : 63.5

រៀបរៀង ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០១៧

វិញ្ញាសា គីមីទី ៣១

វិញ្ញាសាៈ ឯកទេសទី១ គីមីវិទ្យា រយៈពេល ៣ ម៉ោង

ឈ្មោះ..................................លេខបន្ទប់...............លេខតុ.................ហត្ថលេខា.................

(សម្រាប់និស្សិតគីមីត្រៀមប្រលង NIE) Tel: 098 472 472

ដំណោះស្រាយវិញ្ញាសាគីមីវិទ្យា ៣១

១. ក. ចូរកំណត់ចំនួនអេឡិចត្រុងអតិបរិមាដែលមានក្នុងស្រទាប់រងនីមួយៗ 3s, 3d, 4p, 4f, 5f និង 6d។

យើងមានតម្លៃចំនួនកង់ទិចរងជាទូទៅតាងដោយអក្សរ s, p, d, f,.......... ដូចតទៅ

| ℓ | 0 | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|
| ឈ្មោះអរប៊ីតាល់ | s | p | d | f | g | h |

ដូចនេះយើបានចំនួនអេឡិចត្រុងអតិបរិមាក្នុងស្រទាប់រង 3s = $4\ell + 2 = (4 \times 0) + 2 = 2$ អេឡិចត្រុង

ចំនួនអេឡិចត្រុងអតិបរិមាក្នុងស្រទាប់រង 3d = $4\ell + 2 = (4 \times 2) + 2 = 10$ អេឡិចត្រុង

ចំនួនអេឡិចត្រុងអតិបរិមាក្នុងស្រទាប់រង 4p = $4\ell + 2 = (4 \times 1) + 2 = 6$ អេឡិចត្រុង

ចំនួនអេឡិចត្រុងអតិបរិមាក្នុងស្រទាប់រង 4f = $4\ell + 2 = (4 \times 3) + 2 = 14$ អេឡិចត្រុង

ចំនួនអេឡិចត្រុងអតិបរិមាក្នុងស្រទាប់រង 5f = $4\ell + 2 = (4 \times 3) + 2 = 14$ អេឡិចត្រុង

ចំនួនអេឡិចត្រុងអតិបរិមាក្នុងស្រទាប់រង 6d = $4\ell + 2 = (4 \times 2) + 2 = 10$ អេឡិចត្រុង

ខ. ចូរកំណត់ចំនួនអេឡិចត្រុងសរុបក្នុងស្រទាប់រងៈ

១. អាតូម N (Z = 7) ស្រទាប់រង p: $1s^2\ 2s^2\ 2p^3$

ដូចនេះចំនួនអេឡិចត្រុងសរុបក្នុងស្រទាប់រង p មាន 3 អេឡិចត្រុង

២. អាតូម Si (Z = 14) ស្រទាប់រង s: $1s^2\ 2s^2\ 2p^6\ 3s^2\ 3p^2$

ដូចនេះចំនួនអេឡិចត្រុងសរុបក្នុងស្រទាប់រង s មាន 6 អេឡិចត្រុង

៣. អាតូម S (Z = 16) ស្រទាប់ d: $1s^2\ 2s^2\ 2p^6\ 3s^2\ 3p^4$

ដូចនេះគ្មានអេឡិចត្រុងក្នុងស្រទាប់រង d

៤. អ៊ីយ៉ុង $Cl^-$ (Z = 17) ស្រទាប់រង p: $1s^2\ 2s^2\ 2p^6\ 3s^2\ 3p^6$

ដូចនេះចំនួនអេឡិចត្រុងសរុបក្នុងស្រទាប់រង p មាន 12 អេឡិចត្រុង

អាតូម N, Si និង S ជាប្រភេទប៉ារ៉ាម៉ាញ៉េទិច និងអ៊ីយ៉ុង $Cl^-$ ជាប្រភេទដ្យាម៉ាញ៉េទិច។




គ. ក្រុមប្រភេទគីមីដែលអាចជាអ៊ីសូអេឡិចត្រូនិចនឹងគ្នាគឺ:

$Be^{2+}$ និង He ($2e^-$), $F^-$ និង $N^{3-}$ ($10e^-$), $Fe^{2+}$ និង $Co^{3+}$ ($24e^-$), $S^{2-}$ និង Ar ($18e^-$)

២. ក. គណនាថេរល្បឿន រយៈពេលពាក់កណ្ដាលប្រតិកម្ម និង រយៈពេលដែលត្រូវការដើម្បីបំបែក

សមាសធាតុនេះឲ្យអស់ 20 %។ **វិធីទី១** តាមរូបមន្ត $\ln\frac{[A]_0}{[A]_t} = kt$ នាំឲ្យ $K = \frac{1}{t} \times \ln\frac{[A]_0}{[A]_t}$

យើងមានសមាសធាតុនេះដើម 100 % សមាសធាតុនេះបាននៅសល់ 20 % ដូចនេះផលធៀបភាគរយស្មើផលធៀបកំហាប់ $\frac{[A]_0}{[A]_t} = \frac{100}{20} = 5$

យើងបាន $K = \frac{1}{6\ h} \times \ln 5 = \frac{1.609}{6\ h} = 0.27\ h^{-1}$

ដូចនេះថេរល្បឿន $K = 0.27\ h^{-1}$

**Summary of the Kinetics of Zero-Order, First-Order and Second-Order Reactions**

| Order | Rate Law | Concentration-Time Equation | Half-Life |
|---|---|---|---|
| 0 | rate = $k$ | $[A] = [A]_0 - kt$ | $t_{1/2} = \frac{[A]_0}{2k}$ |
| 1 | rate = $k[A]$ | $\ln[A] = \ln[A]_0 - kt$ | $t_{1/2} = \frac{\ln 2}{k}$ |
| 2 | rate = $k[A]^2$ | $\frac{1}{[A]} = \frac{1}{[A]_0} + kt$ | $t_{1/2} = \frac{1}{k[A]_0}$ |

**វិធីទី២** តាមរូបមន្ត $\ln\frac{[A]_t}{[A]_0} = -kt$ នាំឲ្យ $K = -\frac{1}{t} \times \ln\frac{[A]_t}{[A]_0}$

យើងមានសមាសធាតុនេះដើម 100 % សមាសធាតុនេះបាននៅសល់ 20 % ដូចនេះផលធៀបភាគរយ

ស្មើផលធៀបកំហាប់ $\frac{[A]_t}{[A]_0} = \frac{20}{100} = \frac{1}{5}$

យើងបាន $K = -\frac{1}{6\ h} \times \ln\frac{1}{5} = \frac{1.609}{6\ h} = 0.27\ h^{-1}$

ដូចនេះថេរល្បឿន $K = 0.27\ h^{-1}$

គណនារយៈពេលកណ្ដាលប្រតិកម្មនេះ

តាមរូបមន្ត $t_{1/2} = \frac{\ln 2}{k} = \frac{0.693}{0.27\ h^{-1}} = 2.57\ h$

ដូចនេះរយៈពេលពាក់កណ្ដាលប្រតិកម្ម $t_{1/2} = 2.57\ h$

**វិធីទី១** គណនារយៈពេលដែលត្រូវការដើម្បីបំបែកសមាសធាតុនេះឲ្យអស់ 20 %

តាមរូបមន្ត $\ln\frac{[A]_0}{[A]_t} = kt$ នាំឲ្យ $t = \frac{1}{k} \times \ln\frac{[A]_0}{[A]_t}$

យើងមានសមាសធាតុនេះដើម 100 % សមាសធាតុនេះបានបំបែកអស់ 20 % នោះនៅសល់

100 % – 20 % = 80 % ដូចនេះផលធៀបភាគរយស្មើផលធៀបកំហាប់ $\frac{[A]_0}{[A]_t} = \frac{100}{80} = \frac{5}{4}$

យើងបាន $t = \frac{1}{0.27\ h^{-1}} \times \ln\frac{5}{4}$

$= \frac{1}{0.27\ h^{-1}}(\ln 5 - 2\ln 2) = 0.83\ h$

ដូចនេះរយៈពេលដែលត្រូវការដើម្បីបំបែកសមាសធាតុនេះឲ្យអស់ 20% ស្មើ $t = 0.83\ h$

**វិធីទី២** គណនារយៈពេលដែលត្រូវការដើម្បីបំបែកសមាសធាតុនេះឲ្យអស់ 20 %

តាមរូបមន្ត $\ln\frac{[A]_t}{[A]_0} = -kt$ នាំឲ្យ $t = -\frac{1}{k} \times \ln\frac{[A]_t}{[A]_0}$

យើងមានសមាសធាតុនេះដើម 100 % សមាសធាតុនេះបានបំបែកអស់ 20 % នោះនៅសល់

100 % – 20 % = 80 % ដូចនេះផលធៀបភាគរយស្មើផលធៀបកំហាប់ $\frac{[A]_t}{[A]_0} = \frac{80}{100} = \frac{4}{5}$

យើងបាន $t = -\frac{1}{0.27\ h^{-1}} \times \ln\frac{4}{5}$

$= -\frac{1}{0.27\ h^{-1}}(2\ln 2 - \ln 5) = 0.83\ h$

ដូចនេះរយៈពេលដែលត្រូវការដើម្បីបំបែកសមាសធាតុនេះឲ្យអស់ 20% ស្មើ t = 0.83 h

ខ. តើសមាសធាតុនេះនៅសល់ប៉ុន្មាន បន្ទាប់ពីប្រតិកម្មបំបែកអស់ រយៈពេល 200 s បើវាជាប្រតិកម្ម លំដាប់១? **វិធីទី១** តាមរូបមន្ត $\ln\frac{[A]_0}{[A]_t} = kt$ នាំឲ្យ $K = \frac{1}{t} \times \ln\frac{[A]_0}{[A]_t}$

យើងមានសមាសធាតុ A ដើម 100 % សមាសធាតុ A បាននៅសល់ 50 % ដូចនេះផលធៀបភាគរយ ស្មើផលធៀបកំហាប់ $\frac{[A]_0}{[A]_t} = \frac{100}{50} = 2$

$e^{\ln K} = K$

យើងបាន $K = \frac{1}{100\ s} \times \ln 2 = \frac{0.693}{100\ s} = 0.693 \times 10^{-2}\ s^{-1}$

ដូចនេះថេរល្បឿន $K = 0.693 \times 10^{-2}\ s^{-1}$

**វិធីទី២** តាមរូបមន្ត $\ln\frac{[A]_t}{[A]_0} = -kt$ នាំឲ្យ $K = -\frac{1}{t} \times \ln\frac{[A]_t}{[A]_0}$

យើងមានសមាសធាតុ A ដើម 100 % សមាសធាតុ A បាននៅសល់ 50 % ដូចនេះផលធៀបភាគរយ ស្មើផលធៀបកំហាប់ $\frac{[A]_t}{[A]_0} = \frac{50}{100} = \frac{1}{2}$

$e^{\ln K} = K$

យើងបាន $K = \frac{1}{100\ s} \times \ln\frac{1}{2} = \frac{0.693}{100\ s} = 0.693 \times 10^{-2}\ s^{-1}$

ដូចនេះថេរល្បឿន $K = 0.693 \times 10^{-2}\ s^{-1}$

រកបរិមាណសមាសធាតុ A ដែលនៅសល់រយៈពេល 200 s

វិធីទី១ តាមរូបមន្ត $\ln\frac{[A]_t}{[A]_o} = -kt$ នាំឲ្យ $\frac{[A]_t}{[A]_o} = e^{-\left(\frac{\ln 2}{100}\right)200} = \frac{1}{4} = 0.25$

នោះយើងបានសមាសធាតុនៅសល់ 0.25 x 100 % = 25 %

ដូចនេះសមាសធាតុ A នៅសល់ 25 %

វិធីទី២ តាមរូបមន្ត $\ln\frac{[A]_t}{[A]_o} = -kt = -\frac{\ln 2}{t_{\frac{1}{2}}} t = \ln 2^{\left(-\frac{t}{t_{\frac{1}{2}}}\right)}$

នាំឲ្យ $\frac{[A]_t}{[A]_o} = 2^{-\left(\frac{200}{100}\right)} = 2^{-2} = \frac{1}{4} = 0.25$

នោះយើងបានសមាសធាតុនៅសល់ 0.25 x 100 % = 25 %

ដូចនេះសមាសធាតុ A នៅសល់ 25 %

គ. ១. សរសេរសមីការនៃប្រតិកម្មបំបែកស៊ុលផួរីលក្លរ ទៅជាស្ពាន់ធ័រឌីអុកស៊ីត និង ឧស្ម័នក្លរ

$$SO_2Cl_2 \rightarrow SO_2 + Cl_2$$

២. គណនាតម្លៃថេរល្បឿននៃប្រតិកម្មនេះ

តាមរូបមន្ត $t_{1/2} = \frac{\ln 2}{k}$ នាំឲ្យ $K = \frac{\ln 2}{t_{1/2}} = \frac{0.693}{9\ min} = 0.077\ min^{-1}$

ដូចនេះថេរល្បឿន $K = 0.077\ min^{-1}$

៣. គណនាកំហាប់ស៊ុលផូរីលក្លរដែលនៅសល់ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តទៅអស់រយៈពេល 10 នាទី

**វិធីទី១** តាមរូបមន្ត $\ln [A]_t = -kt + \ln [A]_0$

ដោយ $t = 10$ នាទី $k = 0.077\ min^{-1}$ និង $[A]_0 = 0.65\ M$

យើងបាន $\ln [A]_t = -0.077\ min^{-1} \times 10\ min + \ln 0.65$

$= -0.77 - 0.431 = -1.201$

នាំឲ្យ $[A]_t = e^{-1.201} = 0.301\ M$

ដូចនេះយើងបានកំហាប់ស៊ីក្លូប្រូប៉ានដែលនៅសល់ $[A]_t = 0.301\ M$

**វិធីទី២** តាមរូបមន្ត $\ln \frac{[A]_t}{[A]_0} = -kt$ នាំឲ្យ $\frac{[A]_t}{[A]_0} = e^{(-kt)} = e^{(-0.077 \times 10)} = 0.463$

ដូចនេះយើងបានកំហាប់ស៊ីក្លូប្រូប៉ានដែលនៅសល់ $[A]_t = [A]_0 \times 0.463 = 0.301\ M$

៤. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីឲ្យស៊ុលផូរីលក្លរនៅសល់ 4 %?

តាមរូបមន្ត $\ln \frac{[A]_0}{[A]_t} = kt$ នាំឲ្យ $t = \frac{1}{k} \times \ln \frac{[A]_0}{[A]_t}$

យើងមានសមាសធាតុស៊ុលផូរីលក្លរដើម 100 % សមាសធាតុនេះបាននៅសល់ 4 % ដូចនេះផលធៀប

ភាគរយស្មើផលធៀបកំហាប់ $\frac{[A]_0}{[A]_t} = \frac{100}{4} = 25$

យើងបាន $t = \frac{1}{0.077\ min^{-1}} \times \ln 25$

$= \frac{1}{0.077\ min^{-1}} (2 \times \ln 5) = 42$ នាទី

ដូចនេះរយៈពេលដែលត្រូវការ $t = 42\ min$

ភាគរយ A សល់ $= \frac{[A]_t}{[A]_0} \times 100$

យើងបាន $\frac{[A]_0}{[A]_t} = \frac{100}{\text{percent of A remained}}$

ឬ $\frac{[A]_t}{[A]_0} = \frac{\text{percent of A remained}}{100}$

៣. ថ្លឹងសមីការខាងក្រោមនេះឲ្យបានត្រឹមត្រូវ:

ក. $Zn + As_2O_3 + H_2SO_4 \rightarrow AsH_3 + ZnSO_4 + H_2O$

$$\overset{0}{Zn} + \overset{+3\ -2}{As_2O_3} + \overset{+1\ -6\ -2}{H_2SO_4} \longrightarrow \overset{-3\ +1}{AsH_3} + \overset{+2\ -6\ -2}{ZnSO_4} + \overset{+1\ -2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Zn = 0 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol Zn ស្មើ 2 និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $As_2O_3$ ស្មើ 12

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$6\ Zn + As_2O_3 + 6\ H_2SO_4 \rightarrow 2\ AsH_3 + 6\ ZnSO_4 + 3\ H_2O$$

ខ. $$\overset{+2\ +3\ -2}{FeC_2O_4} + \overset{+1\ +7\ -2}{KMnO_4} + \overset{+1\ +6\ -2}{H_2SO_4} \longrightarrow \overset{+3\ +6\ -2}{Fe_2(SO_4)_3} + \overset{+4\ -2}{CO_2} + \overset{+2\ +6\ -2}{MnSO_4} + \overset{+1\ +6\ -2}{K_2SO_4} + \overset{+1\ -2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Fe = +2 និង C = +3 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol $FeC_2O_4$ ស្មើ 3 និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KMnO_4$ ស្មើ 5

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

ខ. $10\ FeC_2O_4 + 6\ KMnO_4 + 24\ H_2SO_4 \rightarrow 5\ Fe_2(SO_4)_3 + 20\ CO_2 + 6\ MnSO_4 + 3\ K_2SO_4 + 24\ H_2O$

គ. $Sb_2S_3 + 3\ Na_2CO_3 + 6\ C \rightarrow 2\ Sb + 3\ Na_2S + 9\ CO$ (មជ្ឈដ្ឋានអាស៊ីត)

ឃ. $$\overset{+5\ -2}{XO_2^+} + \overset{+3\ -2}{YO^+} \longrightarrow \overset{+5/2\ -2}{X_2O_4^{3-}} + \overset{-1}{Y^-} + \overset{+4\ -2}{Y_3O_7^{2-}}$$ (មជ្ឈដ្ឋានបាស)

ចំនួនអុកស៊ីតកម្ម ($XO_2^+$) ថយចុះស្មើ 5 និងចំនួនអុកស៊ីតកម្ម ($YO^+$) ថយចុះស្មើ 4 ដូចនេះចំនួនអុកស៊ីតកម្មថយចុះសរុបក្នុងស្មើ (5 + 4 = 9) និងចំនួនអុកស៊ីតកម្មកើនសរុបស្មើ 3

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$2\,XO_2^{+} + 10\,YO^{+} \rightarrow X_2O_4^{3-} + Y^{-} + 3\,Y_3O_7^{2-}$$

ថ្លឹងបន្ទុក: ខាងឆ្វេង 2(+1) + 10(+1) =12 ខាងស្តាំ –3 + (–1) + 3(–2) = –10

ដូចនេះយើងត្រូវថែម 22 $OH^-$ ខាងឆ្វេងដើម្បីឲ្យបន្ទុកស្មើគ្នា

$$22\,OH^{-} + 2\,XO_2^{+} + 10\,YO^{+} \rightarrow X_2O_4^{3-} + Y^{-} + 3\,Y_3O_7^{2-} + 11H_2O$$ (មជ្ឈដ្ឋានបាស)

## ថ្លឹងសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

## Balancing by using method of half-reaction

ពាក់កណ្តាលលំនាំរេដុកម្ម

$$2\,XO_2^{+} + 5\,e^{-} \rightarrow X_2O_4^{3-}$$

$$YO^{+} + H_2O + 4\,e^{-} \rightarrow Y^{-} + 2\,OH^{-}$$

យើងបានពាក់កណ្តាលលំនាំរេដុកម្មសរុប

$$2\,XO_2^{+} + YO^{+} + H_2O + 9\,e^{-} \rightarrow X_2O_4^{3-} + Y^{-} + 2\,OH^{-}$$

ពាក់កណ្តាលលំនាំអុកស៊ីតកម្ម

$$3\,YO^{+} + 8\,OH^{-} \rightarrow Y_3O_7^{2-} + 4\,H_2O + 3\,e^{-}$$

ដូចនេះសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

1. For an atom in its elemental form (Na, $O_2$.etc.): O.N. = 0

2. For a monatomic ion O.N.= ion charge ( with the sign before the numeral)

3. The sum of O.N. values for the atoms in a molecule or formula unit of a compound equals 0.

The sum of O.N. values for the atoms in polyatomic ion equals the ion's charge.

4. For Group 1A: O.N. = + 1 in all compounds

5. For Group 2A: O.N. = + 2 in all compounds

6. For hydrogen O.N. = +1 in combination with nonmetals. O.N. = -1 in combination with metals.

7. For fluorine: O.N. = -1 in all compounds.

8. For oxygen: O.N. = -1 in peroxide

O.N. = -2 in all other compounds (except with F)

$$22\,OH^{-} + 2\,XO_2^{+} + 10\,YO^{+} \rightarrow X_2O_4^{3-} + Y^{-} + 3\,Y_3O_7^{2-} + 11H_2O$$ (មជ្ឈដ្ឋានបាស)

## វិធីកំណត់លេខមេគុណ $OH^-$ (Method for Assigning hydroxide ion coefficients)

១. កំណត់ចំនួនអុកស៊ីតកម្មអាតូម (ចំពោះអាតូមដែលមានចំនួនអុកស៊ីតកម្មប្រែប្រួលតែប៉ុណ្ណោះ)

២. កំណត់បម្រែបម្រួលចំនួនអុកស៊ីតកម្មរបស់អាតូម (n.o ថយវាចាប់យកអេឡិចត្រុង n.o កើនវាបោះបង់អេឡិចត្រុង)

៣. គណនាបន្ទុកសរុបនៅអង្គដែលគ្មាន $OH^-$ រួចថែមលេខមេគុណ $OH^-$ ដើម្បីឲ្យបន្ទុកស្មើគ្នា

(Kimsrea's First Method) (20/01/2020)

Step1 $3\ YO^+ + OH^- \rightarrow Y_3O_7^{2-} + H_2O$

n.o(Y)=+3 n.o(Y)=+4

Step2 $\Delta$n.o(Y)=+4 –(+3) =+1

ចំនួនអុកស៊ីតកម្មកើន ដោយ Y ១ កើន +1 នោះ Y ៣ កើន +3 ដូចនេះ Y វានឹងបោះបង់ ៣អេឡិចត្រុង

Step3 $3\ YO^+ + OH^- \rightarrow Y_3O_7^{2-} + H_2O$

ដោយចំនួនអុកស៊ីតកម្ម Y កើន +3 នោះយើងត្រូវថែម៣អេឡិចត្រុងខាងស្តាំ (វាបោះបង់អេឡិចត្រុង)

ដូចនេះយើងបាន $3\ YO^+ + OH^- \rightarrow Y_3O_7^{2-} + H_2O + 3\ e^-$

ថ្លឹងបន្ទុកៈ ខាងឆ្វេង 3(+1) =+3 ខាងស្តាំ –2 + 3(–1) = –5

ដូចនេះយើងត្រូវថែម 8 $OH^-$ ខាងឆ្វេងដើម្បីឲ្យបន្ទុកស្មើគ្នា

ដូចនេះសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

$$3\ YO^+ + 8\ OH^- \rightarrow Y_3O_7^{2-} + 4\ H_2O + 3\ e^-$$

វិធីកំណត់លេខមេគុណ $OH^-$ (Method for Assigning hydroxide ion coefficients)

(Kimsrea's Second Method) (20/01/2020)

១. សរសេរកន្លះសមីការដែលមិនមានលំនឹងដោយបន្ថែមអ៊ីដ្រុកស៊ីត ($OH^-$) អង្គខ្វះអាតូមអុកស៊ីសែន (O)

ដោយបន្ថែម $H_2O$ នៅអង្គណាខ្វះអាតូមអ៊ីដ្រូសែន (H)

$3\ YO^+ + OH^- \rightarrow Y_3O_7^{2-} + H_2O$

២. តាងអថេរ æ ជាមេគុណ $OH^-$ (æ$OH^-$) និង $\frac{æ}{2}$ ជាមេគុណ $H_2O$ ($\frac{æ}{2}$ $H_2O$)

$3\ YO^+ +$ æ$OH^- \rightarrow Y_3O_7^{2-} + \frac{æ}{2} H_2O$

ករណីគ្មានអាតូមអ៊ីដ្រូសែន

អង្គដែលមានអ៊ីដ្រុកស៊ីត

៣. ថ្លឹងចំនួនអាតូមអុកស៊ីសែនដើម្បីរកតម្លៃអថេរ æ

$$3\ YO^{+} + æOH^{-} \rightarrow Y_3O_7^{2-} + \frac{æ}{2} H_2O$$

$3 + æ = 7 + \frac{æ}{2}$ យើងបាន $æ = 8$

$$3\ YO^{+} + 8\ OH^{-} \rightarrow Y_3O_7^{2-} + 4\ H_2O$$

ថ្លឹងបន្ទុកៈ ខាងឆ្វេង 3(+1) +(–8) =–5 ខាងស្តាំ –2

ដូចនេះយើងត្រូវថែម $3e^{-}$ ខាងអង្គដែលមានបន្ទុកធំដើម្បីឲ្យបន្ទុកស្មើគ្នា។

$$3\ YO^{+} + 8\ OH^{-} \rightarrow Y_3O_7^{2-} + 4\ H_2O + 3\ e^{-}$$

ង. $124\ HCl + 11\ K_2Cr_2O_7 + 6\ Cu_3P \rightarrow 18\ CuCl_2 + 6\ H_3PO_4 + 22\ CrCl_3 + 53\ H_2O + 22\ KCl$

(មជ្ឈដ្ឋានអាស៊ីតសណ្ឋានជាម៉ូលេគុល)

$$\overset{+1\ -3}{Cu_3P} + \overset{+6\ -2}{Cr_2O_7^{2-}} \longrightarrow \overset{+2}{Cu^{2+}} + \overset{+1\ +5\ -2}{H_3PO_4} + \overset{+3}{Cr^{3+}}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1 និង P = –3 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 11 ក្នុង 1 mol $Cu_3P$ និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 6 ក្នុង 1 mol $Cr_2O_7^{2-}$

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$124\ H^{+} + 6\ Cu_3P + 11\ Cr_2O_7^{2-} \rightarrow 18\ Cu^{2+} + 6\ H_3PO_4 + 22\ Cr^{3+} + 53\ H_2O$$

ខាងឆ្វេងថែម $124\ Cl^{-}, 22\ K^{+}$ ខាងស្តាំថែម $124\ Cl^{-}, 22\ K^{+}$

$$124\ HCl + 11\ K_2Cr_2O_7 + 6\ Cu_3P \rightarrow 18\ CuCl_2 + 6\ H_3PO_4 + 22\ CrCl_3 + 53\ H_2O + 22\ KCl$$

## ថ្លឹងសមីការតុល្យការតាមវិធីពាក់កណ្ដាលប្រតិកម្ម

**Balancing by using method of half-reaction**

ពាក់កណ្ដាលលំនាំរេដុកម្ម

$Cu_3P + 4\ H_2O \rightarrow 3\ Cu^{2+} + H_3PO_4 + 5\ H^+ + 11\ e^-$

ពាក់កណ្ដាលលំនាំរេដុកម្ម

$Cr_2O_7^{2-} + 14\ H^+ + 6\ e^- \rightarrow 2\ Cr^{3+} + 7\ H_2O$

ដូចនេះសមីការតុល្យការតាមវិធីពាក់កណ្ដាលប្រតិកម្ម

$124\ H^+ + 6\ Cu_3P + 11\ Cr_2O_7^{2-} \rightarrow 18\ Cu^{2+} + 6\ H_3PO_4 + 22\ Cr^{3+} + 53\ H_2O$

ខាងឆ្វេងថែម $124\ Cl^-, 22\ K^+$ ខាងស្ដាំថែម $124\ Cl^-, 22\ K^+$

$124\ HCl + 11\ K_2Cr_2O_7 + 6\ Cu_3P \rightarrow 18\ CuCl_2 + 6\ H_3PO_4 + 22\ CrCl_3 + 53\ H_2O + 22\ KCl$

ថ្លឹងតាមចំនួនបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\ -1}{HCl} + \overset{+1\ +6\ -2}{K_2Cr_2O_7} + \overset{+1\ -3}{Cu_3P} \longrightarrow \overset{+2\ -1}{CuCl_2} + \overset{+1\ +5\ -2}{H_3PO_4} + \overset{+3\ -1}{CrCl_3} + H_2O + KCl$$

ចំនួនអុកស៊ីតកម្មកើនសរុប 1mol $Cu_3P$ ស្មើ +1 តែក្នុងម៉ូលេគុល $Cu_3P$ មាន **៣អាតូម Cu** នោះចំនួនចំនួនអុកស៊ីតកម្មកើនសរុបស្មើ ៣

ចំនួនអុកស៊ីតកម្មកើនសរុប 1mol $Cu_3P$ ស្មើ (+5– (–3) =8 តែក្នុងម៉ូលេគុល $Cu_3P$ មាន **១អាតូម P** នោះចំនួនចំនួន អុកស៊ីតកម្មកើនសរុបស្មើ ៨

ដូចនេះចំនួនអេឡិចត្រុងកើនសរុបស្មើ ១១

ចំនួនអុកស៊ីតកម្មថយចុះសរុប 1mol $K_2Cr_2O_7$ ស្មើ +3–(+6)=+3 តែក្នុងម៉ូលេគុល $K_2Cr_2O_7$ មាន **២អាតូម Cr** នោះចំនួនចំនួន អុកស៊ីតកម្មកើនសរុបស្មើ ៦

$$124\ HCl + 11\ K_2Cr_2O_7 + 6\ Cu_3P \rightarrow 18\ CuCl_2 + 6\ H_3PO_4 + 22\ CrCl_3 + 53\ H_2O + 22\ KCl$$

ច. $CuSCN + KIO_3 + HCl \rightarrow CuSO_4 + KCl + HCN + ICl + H_2O$

## វិធីទី១ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,-2\,-4\,+5}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –2, C = –4 និង N = +5 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 17 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 10 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (17 – 10 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\ CuSCN + 7\ KIO_3 + 14\ HCl \rightarrow 4\ CuSO_4 + 7\ KCl + 4\ HCN + 7\ ICl + 5\ H_2O$$

## វិធីទី២ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,-2\,+4\,-3}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –2, C = +4 និង N = –3 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 9 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 2 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (9 – 2 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\,CuSCN + 7\,KIO_3 + 14\,HCl \rightarrow 4\,CuSO_4 + 7\,KCl + 4\,HCN + 7\,ICl + 5\,H_2O$$

## វិធីទី៣ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,+4\,-4\,-1}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = +4, C = –4 និង N = –1 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 11 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 4 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (11 – 4 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\,CuSCN + 7\,KIO_3 + 14\,HCl \rightarrow 4\,CuSO_4 + 7\,KCl + 4\,HCN + 7\,ICl + 5\,H_2O$$

## វិធីទី៤ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,-3\,+2\,0}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –3, C = +2 និង N = 0 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 12 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 5 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (12 – 5 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\,CuSCN + 7\,KIO_3 + 14\,HCl \rightarrow 4\,CuSO_4 + 7\,KCl + 4\,HCN + 7\,ICl + 5\,H_2O$$

## វិធីទី៥ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\ -4\ +2\ +1}{CuSCN} + \overset{+1\ +5\ -2}{KIO_3} + \overset{+1\ -1}{HCl} \longrightarrow \overset{+2\ +6\ -2}{CuSO_4} + \overset{+1\ -1}{KCl} + \overset{+1\ +4\ -5}{HCN} + \overset{+1\ -1}{ICl} + \overset{+1\ -2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –4, C = +2 និង N = +1 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 13 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 6 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (13 – 6 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\ CuSCN + 7\ KIO_3 + 14\ HCl \rightarrow 4\ CuSO_4 + 7\ KCl + 4\ HCN + 7\ ICl + 5\ H_2O$$

## វិធីទី៦ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\ -8\ +2\ +5}{CuSCN} + \overset{+1\ +5\ -2}{KIO_3} + \overset{+1\ -1}{HCl} \longrightarrow \overset{+2\ +6\ -2}{CuSO_4} + \overset{+1\ -1}{KCl} + \overset{+1\ +4\ -5}{HCN} + \overset{+1\ -1}{ICl} + \overset{+1\ -2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –8, C = +2 និង N = +5 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 17 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 10 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (17 – 10 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\ CuSCN + 7\ KIO_3 + 14\ HCl \rightarrow 4\ CuSO_4 + 7\ KCl + 4\ HCN + 7\ ICl + 5\ H_2O$$

## វិធីទី៧ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,-5\,+2\,+2}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –5, C = +2 និង N = +2 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 14 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 7 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (14 – 7 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\,CuSCN + 7\,KIO_3 + 14\,HCl \rightarrow 4\,CuSO_4 + 7\,KCl + 4\,HCN + 7\,ICl + 5\,H_2O$$

## វិធីទី៨ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,-7\,+4\,+2}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –7, C = +4 និង N = +2 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 14 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 7 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (14 – 7 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\,CuSCN + 7\,KIO_3 + 14\,HCl \rightarrow 4\,CuSO_4 + 7\,KCl + 4\,HCN + 7\,ICl + 5\,H_2O$$

## វិធីទី៩ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,-6\,0\,+5}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –6, C = 0 និង N = +5 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 17 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 10 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (17 – 10 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\,CuSCN + 7\,KIO_3 + 14\,HCl \rightarrow 4\,CuSO_4 + 7\,KCl + 4\,HCN + 7\,ICl + 5\,H_2O$$

## វិធីទី១០ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\;\;0\,-1\,0}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –5, C = +4 និង N = 0 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 12 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 5 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (12 – 5 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\,CuSCN + 7\,KIO_3 + 14\,HCl \rightarrow 4\,CuSO_4 + 7\,KCl + 4\,HCN + 7\,ICl + 5\,H_2O$$

សាកល្បងថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្មតាមលទ្ធភាពដែលអាចធ្វើបាន

## វិធីទី១១ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,-5\,+4\,0}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –5, C = +4 និង N = 0 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 12 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 5 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (12 – 5 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\ CuSCN + 7\ KIO_3 + 14\ HCl \rightarrow 4\ CuSO_4 + 7\ KCl + 4\ HCN + 7\ ICl + 5\ H_2O$$

## វិធីទី១២ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\;\;0\;0\,-1}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = 0, C = 0 និង N = –1 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 11 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 4 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (11 – 4 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\ CuSCN + 7\ KIO_3 + 14\ HCl \rightarrow 4\ CuSO_4 + 7\ KCl + 4\ HCN + 7\ ICl + 5\ H_2O$$

## វិធីទី១៣ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\ -1\ 0\ 0}{CuSCN} + \overset{+1\ +5\ -2}{KIO_3} + \overset{+1\ -1}{HCl} \longrightarrow \overset{+2\ +6\ -2}{CuSO_4} + \overset{+1\ -1}{KCl} + \overset{+1\ +4\ -5}{HCN} + \overset{+1\ -1}{ICl} + \overset{+1\ -2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –1, C =0 និង N = 0 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 11 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 4 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (11 – 4 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\ CuSCN + 7\ KIO_3 + 14\ HCl \rightarrow 4\ CuSO_4 + 7\ KCl + 4\ HCN + 7\ ICl + 5\ H_2$$

## វិធីទី១៤ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\ -1\ -1\ +1}{CuSCN} + \overset{+1\ +5\ -2}{KIO_3} + \overset{+1\ -1}{HCl} \longrightarrow \overset{+2\ +6\ -2}{CuSO_4} + \overset{+1\ -1}{KCl} + \overset{+1\ +4\ -5}{HCN} + \overset{+1\ -1}{ICl} + \overset{+1\ -2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –1, C = –1 និង N =+1 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 13 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 6 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (13–6 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\ CuSCN + 7\ KIO_3 + 14\ HCl \rightarrow 4\ CuSO_4 + 7\ KCl + 4\ HCN + 7\ ICl + 5\ H_2O$$

## វិធីទី១៥ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,-1\,+1\,-1}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –1, C = +1 និង N = –1 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 11 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 4 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (11–4 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\,CuSCN + 7\,KIO_3 + 14\,HCl \rightarrow 4\,CuSO_4 + 7\,KCl + 4\,HCN + 7\,ICl + 5\,H_2O$$

## វិធីទី១៦ ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+1\,-2\,+2\,-1}{CuSCN} + \overset{+1\,+5\,-2}{KIO_3} + \overset{+1\,-1}{HCl} \longrightarrow \overset{+2\,+6\,-2}{CuSO_4} + \overset{+1\,-1}{KCl} + \overset{+1\,+4\,-5}{HCN} + \overset{+1\,-1}{ICl} + \overset{+1\,-2}{H_2O}$$

បើយើងកំណត់យកចំនួនអុកស៊ីតកម្ម Cu = +1, S = –2, C = +2 និង N = –1 នោះចំនួនអុកស៊ីតកម្មកើនសរុបស្មើ 11 និងចំនួនអុកស៊ីតកម្មថយចុះសរុបស្មើ 4 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuSCN ស្មើ (11–4 = 7) និងចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $KIO_3$ ស្មើ 4

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$4\,CuSCN + 7\,KIO_3 + 14\,HCl \rightarrow 4\,CuSO_4 + 7\,KCl + 4\,HCN + 7\,ICl + 5\,H_2O$$

៤. គណនាសម្ពាធសរុបក្នុងបាឡុងនេះ

រកចំនួនម៉ូលនៃអង្គធាតុប្រតិករនីមួយៗ C និង $O_2$

តាមរូបមន្ត $n_C = \frac{m_C}{M_C} = \frac{5.72\ g}{12\ g/mol} = 0.476\ mol$

$$n_{O_2} = \frac{m_{O_2}}{M_{O_2}} = \frac{68.4\ g}{32\ g/mol} = 2.14\ mol$$

ដោយផលធៀបម៉ូលរវាង C និង $O_2$ ក្នុងសមីការតុល្យការសមាមាត្រ 1:1 ដូចនេះ C ជាអង្គធាតុប្រតិករកំណត់

ចំនួនម៉ូល $O_2$ សល់ក្រោយប្រតិកម្ម = 2.14 mol – 0.476 mol = 1.664 mol

តាមសមីការ $n_{CO_2}$ (កកើត) = $n_C$ = 0.476 mol

យើងបានចំនួនម៉ូលឧស្ម័នសរុបក្នុងបាឡុង = 0.476 mol + 1.664 mol = 2.14 mol

តាមរូបមន្ត PV = nRT នាំឲ្យ $P = \frac{nRT}{V} = \frac{2.14\ mol \times 0.0821\ L.\frac{atm}{mol.K} \times (182+273)\ K}{8\ L} = 9.99\ atm$

ដូចនេះសម្ពាធក្នុងបាឡុង P = 9.99 atm

៥. ចូរគណនាភាគរយស័ង្កសីក្នុងសំលោហៈនេះ

សមីការសំលោហៈ Cu-Zn ប្រតិកម្មជាមួយអាស៊ីតក្លរីឌ្រិច

$$Zn\ (s) + 2\ HCl\ (aq) \rightarrow ZnCl_2\ (aq) + H_2\ (g)$$

$Cu\ (s) + HCl\ (aq) \rightarrow$ គ្មានប្រតិកម្ម

រកចំនួនម៉ូលឧស្ម័នអ៊ីដ្រូសែនដែលទទួលបាន

តាមរូបមន្ត PV = nRT នាំឲ្យ $n = \frac{PV}{RT}$

ដោយ $P = 728\ mmHg = 728\ mmHg \times \frac{1\ atm}{760\ mmHg} = 0.96\ atm$,   V = 1.26 L

R = 0.0821 L.atm/ mol.K,   T = 22 ºC + 273 = 295 K

យើងបានចំនួនម៉ូល $n_{H_2} = \frac{0.96\ atm \times 1.26\ L}{0.0821\ \frac{L.atm}{mol.K} \times 295\ K} = 0.05\ mol$

ដោយផលធៀបម៉ូលរវាង Zn និង $H_2$ ក្នុងសមីការតុល្យការសមាមាត្រ 1:1 ដូចនេះចំនួនម៉ូល

**Zn = 0.05 mol នាំឲ្យម៉ាស Zn = 0.05 mol x 65.3 g/mol = 3.265 g Zn**

យើងបានភាគរយស័ង្កសីក្នុងសំលោហៈ $\% \ Zn = \frac{3.265 \ g}{6.11 \ g} \times 100 \ \% = 53.44 \ \%$

## រៀបរៀង និងចងក្រងដោយៈ ហួន គឹមស្រ៊ា

**Tel: 098 472 472**

គេថាមានចិត្តអធ្យាស្រ័យដល់គេគឺអាចទទួលបានអ្វីៗទាំងអស់បានសុខរហូត

យ៉ាងនេះទើបជាការត្រឹមត្រូវបំផុត

**No part of this compilation may be reproduced or distributed in any form or by any means, or stored in a database or retrieval system, without the prior written consent.**

**Prepared by Houn Kimsrea**

**May 18, 2018**

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី............

វិញ្ញាសា គីមីទី ៣២

រៀបរៀង ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១៧

វិញ្ញាសា៖ ឯកទេសទី១ គីមីវិទ្យា រយៈពេល ៣ ម៉ោង

ឈ្មោះ..................................លេខបន្ទប់...............លេខតុ.................ហត្ថលេខា.................

សម្រាប់និស្សិតគីមីត្រៀមប្រលង NIE Tel: 098 472 472

## ប្រធានវិញ្ញាសាគីមីវិទ្យាទី ៣២

I. ចូរហៅឈ្មោះសមាសធាតុ និង អ៊ីសូតូបខាងក្រោមនេះឲ្យបានត្រឹមត្រូវ:

$[Cr(NH_3)_6](NO_3)_3$, $^{199}_{80}Hg$, $Co(CO)_4$, $^{200}_{80}Hg$, $K_2[Zn(OH)_4]$, $^{2}_{1}H$,
$[Fe(H_2O)_4(OH)_2]^+$, $^{3}_{1}H$, $N_2O_5$, $Hg_2I_2$, $H_2CrO_4$, $Cl_2O_7$

តើអ៊ីសូតូប អ៊ីសូមែរ និងអ៊ីសូអេឡិចត្រូនិចខុសគ្នាដូចម្តេច? ចូរឲ្យឧទាហរណ៍បញ្ជាក់។

II. ក. ចូរសរសេរបាយអេឡិចត្រុងនៃអាតូម និង អ៊ីយ៉ុងនីមួយៗដូចតទៅ: Fe (Z = 26), $Fe^{2+}$,

$Ni^{2+}$ (Z = 28), $Cu^{2+}$ (Z = 29), $Pt^{2+}$ (Z = 78), $Pt^{4+}$, Co (Z = 27)

ខ. តើអាតូម និង អ៊ីយ៉ុងនីមួយៗមានអេឡិចត្រុងសេរីសរុបប៉ុន្មាន?

គ. តើអាតូម និង អ៊ីយ៉ុងណាខ្លះខាងលើ ជាប៉ារ៉ាម៉ាញ៉េទិច និង ដ្យាម៉ាញ៉េទិច។

ឃ. តើក្រុមប្រភេទគីមីខាងក្រោមណាខ្លះជាអ៊ីសូអេឡិចត្រូនិចនឹងគ្នា?

III. ក. គេតាងនុយក្លេអូទីតដោយនិមិត្តសញ្ញា $^{A}_{Z}X$ ដែល X ជានិមិត្តសញ្ញាធាតុគីមី A ជាចំនួនម៉ាស និង Z ជាលេខលំដាប់ ឬ លេខអាតូម។ ចូរបកស្រាយថាធាតុគីមី X មានម៉ាសម៉ូលេគុល $M \approx A$ (g/mol) ដោយសន្មត់ថាម៉ាស 1 ប្រូតុង = ម៉ាស 1 ណឺត្រុង = $1.67 \times 10^{-27}$ kg, $N_A = 6.022 \times 10^{23}$ អាតូម

ខ. ចូរបកស្រាយថា 1 g = $6.022 \times 10^{23}$ amu (ដែល amu ជាខ្នាតម៉ាសអាតូម)។

តើ $3.01 \times 10^{23}$ amu មានប៉ុន្មានក្រាម? តើ 8.4 g មានប៉ុន្មាន amu? (ខែកញ្ញា ឆ្នាំ ២០១៥)

IV. ថ្មពិលមួយផ្សំដោយកន្លះពិលពីរ ។ កន្លះពិលទីមួយផ្សំឡើងដោយអេឡិចត្រូតនិចលត្រាំក្នុងសូលុយ

ស្បុងល្បាយដែលមាន $KMnO_4$ 0.1 M, $MnCl_2$ 0.2 M និង HCl 0.1 M និង កន្លះពិលទីពីរផ្សំឡើងដោយអេឡិចត្រូតនិចលត្រាំក្នុងសូលុយស្យុងល្បាយដែលមាន $K_2Cr_2O_7$ 0.1 M, $CrCl_3$ 0.2 M HCl 0.1 M។ គណនាប៉ូតង់ស្យែលអេឡិចត្រូតនៃកន្លះពិលនីមួយៗ និង គណនាកម្លាំងអគ្គីសនីចលកនៃថ្មពិលនេះ។ (២៨ ខែកញ្ញា ឆ្នាំ ២០១១) គេឲ្យ: $E^\circ(MnO_4^- / Mn^{2+})=1.51$ V និង $E^\circ(Cr_2O_7^{2-} / Cr^{3+}) = 1.33$ V, log 2 = 0.3

V. ប្រតិកម្មបំបែកអ៊ីដ្រូសែនពែអុកស៊ីត ទៅជាឧស្ម័នអុកស៊ីសែន និង ទឹក គឺជាប្រតិកម្មលំដាប់ ១ ដែលមានតម្លៃថេរល្បឿនស្មើ $6.4 \times 10^{-5}$ $s^{-1}$។

១. ចូរសរសេរសមីការនៃប្រតិកម្មបំបែកអ៊ីដ្រូសែនពែអុកស៊ីត ទៅជាឧស្ម័នអុកស៊ីសែន និង ទឹក

២. តើតម្លៃរយៈពេល (នាទី) ពាក់កណ្ដាលប្រតិកម្មបំបែកនេះស្មើប៉ុន្មាន?

៣. តើអ៊ីដ្រូសែនពែអុកស៊ីតបំបែកអស់ប៉ុន្មានភាគរយ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តអស់រយៈពេល 600 s។

៤. តើអ៊ីដ្រូសែនពែអុកស៊ីតបំបែកអស់ប៉ុន្មានភាគរយ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តអស់រយៈពេល 450 s។

៥. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីឲ្យអ៊ីដ្រូសែនពែអុកស៊ីតសល់ 5 %?

(គេឲ្យ: $e^{-0.0384} = 0.962$; ln 2 = 0.693; ln 5 = 1.609; $e^{-0.0288} = 0.972$)

VI. ១. ធាតុអ៊ុយរ៉ាញ៉ូមត្រូវបានគេបានញែកចេញពីអ៊ីសូតូបកូនតូរ្យ៉ូម (daughter isotope thorium) ដោយរំលាយភាគសំណាកក្នុងសូលុយស្យុងអាស៊ីត បន្ទាប់មក បន្ថែមសូលុយស្យុងសូដ្យូមអ៊ីយ៉ូឌូដើម្បីបង្កើតកករតូរ្យ៉ូម (III) អ៊ីយ៉ូឌូក្នុងសូលុយស្យុង។

ក. ចូរសរសេរសមីការតាងប្រតិកម្មគីមីដែលបង្កើតកករតូរ្យ៉ូម (III) អ៊ីយ៉ូឌូក្នុងសូលុយស្យុងនេះ

ខ. បើគេរំលាយអ៊ីយ៉ុង $Th^{3+}$ 567 mg ក្នុងសូលុយស្យុងអាស៊ីត។ តើគេចាំបាច់ត្រូវការសូលុយស្យុងសូដ្យូមអ៊ីយ៉ូឌូ 0.50 M ប៉ុន្មានមីលីលីតដើម្បីបង្កើតកករអ៊ីយ៉ុង $Th^{3+}$ ឲ្យអស់ក្នុងសូលុយស្យុង?

២. តូរ្យ៉ូម (IV) អុកស៊ីតត្រូវបានគេរំលាយក្នុងសូលុយស្យុងអាស៊ីតក្លរីឌ្រិច។ ចូរសរសេរសមីការតាងប្រតិកម្មគីមី និង តើគេចាំបាច់ត្រូវការសូលុយស្យុងអាស៊ីតក្លរីឌ្រិច 1.55 M ប៉ុន្មានមីលីលីតដើម្បីរំលាយអុកស៊ីតនេះ 10.56 g ឲ្យអស់? (គេឲ្យម៉ាសអាតូមធៀប: Th = 232)

ចម្លើយប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី............

រៀបរៀង ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ២០១៧

វិញ្ញាសា គីមីទី ៣២

វិញ្ញាសា៖ ឯកទេសទី១ គីមីវិទ្យា រយៈពេល ៣ ម៉ោង

ឈ្មោះ.................................លេខបន្ទប់..............លេខតុ................ហត្ថលេខា.................

(សម្រាប់និស្សិតគីមីត្រៀមប្រលង NIE) Tel: 098 472 472

## ដំណោះស្រាយវិញ្ញាសាគីមីវិទ្យាទី ៣២

I. អិចសាអាមីនក្រូម(III)នីត្រាត, $[Cr(NH_3)_6](NO_3)_3$

ការពន្យល់: លីកង់អាមីន (ammine) មានរូបមន្ត $NH_3$

ដោយសមាសធាតុណឺតនោះផលបូកបន្ទុក(ចំនួនអុកស៊ីតកម្ម)សរុបស្មើសូន្យ យើងអាចសរសេរបាន៖

n.o(Cr) + (0)x 6 + 3(–1) = 0 នាំឲ្យ n.o(Cr) = +3 ព្រោះ $NH_3$ ជាលីកង់ណឺត (neutral ligand) មានបន្ទុកស្មើសូន្យ និងបន្ទុកនីត្រាតស្មើ –1។

ហៅឈ្មោះកុំផ្លិចបន្ទុកវិជ្ជមានមុន កុំផ្លិចបន្ទុកអវិជ្ជមានក្រោយ នោះយើងអាចសរសេរបាន៖

$[Cr(NH_3)_6]^{3+}$ មានឈ្មោះអ៊ីយ៉ុងអិចសាអាមីនក្រូម(III)

បន្ទុករបស់អ៊ីយ៉ុងកុំផ្លិចវិជ្ជមានត្រូវស្មើ +3 ព្រោះកុំផ្លិចនេះផ្សំបង្គពីអ៊ីយ៉ុងនីត្រាត (បន្ទុកស្មើ –1) ចំនួន 3

លេខរ៉ូម៉ាំង III តំណាងឲ្យចំនួនអុកស៊ីតកម្ម +3 របស់លោហៈក្រូមដែលមានក្នុង $[Cr(NH_3)_6](NO_3)_3$

ដូចនេះអិចសាអាមីនក្រូម(III)នីត្រាតមានរូបមន្ត $[Cr(NH_3)_6](NO_3)_3$

បារត–199, របៀបហៅឈ្មោះអ៊ីសូតូម

សរសេរឈ្មោះរបស់ធាតុដោយភ្ជាប់ជាមួយសញ្ញា (–) និងម៉ាសអាតូម

តេត្រាកាបូនីលកូបាល់(0) ឬ កូបាល់តេត្រាកាបូនីល $Co(CO)_4$,

ម៉ូលេគុលនេះជាកុំផ្លិចណឺត (neutral complex) ព្រោះបន្ទុក Co ស្មើ 0 ដោយសារ CO ជាលីកង់ណឺត (neutral ligand) មានបន្ទុកស្មើសូន្យ

ដោយកុំផ្លិចណឺតនោះផលបូកបន្ទុក (ចំនួនអុកស៊ីតកម្ម) សរុបស្មើសូន្យ។ យើងអាចសរសេរបាន:

n.o(Co) +(0x4) = 0 នាំឲ្យ n.o(Co) = 0 ព្រោះ CO ជាលីកង់ណឺត (neutral ligand) មានបន្ទុកស្មើសូន្យ

ដូចនេះ $Co(CO)_4$ មានឈ្មោះថា តេត្រាកាបូនីលកូបាល់(0) ឬ កូបាល់តេត្រាកាបូនីល។

**បារត–200,**

**ប៉ូតាស្យូមតេត្រាអ៊ីដ្រុកសូសាំងកាត(II), $K_2[Zn(OH)_4]$,**

ការពន្យល់: ហៅឈ្មោះកុំផ្លិចបន្ទុកវិជ្ជមានមុន កុំផ្លិចបន្ទុកអវិជ្ជមានក្រោយ នោះយើងអាចសរសេរបាន:

$[Zn(OH)_4]^{2-}$ មានឈ្មោះថា អ៊ីយ៉ុងតេត្រាអ៊ីដ្រុកសូសាំងកាត(II)

លីកង់អ៊ីដ្រុកសូ (Hydroxo) មានបន្ទុកស្មើ–1 ប៉ូតាស្យូមមានបន្ទុកស្មើ +1

បន្ទុករបស់អ៊ីយ៉ុងកុំផ្លិចអវិជ្ជមានត្រូវស្មើ –2 ព្រោះកុំផ្លិចនេះផ្សំបង្កពីអ៊ីយ៉ុងប៉ូតាស្យូមចំនួន 2

នោះចំនួនអុកស៊ីតកម្ម Zn មានក្នុង $[Zn(OH)_4]^{2-}$ ស្មើ n.o(Zn) + 4(–1) = –2 នាំឲ្យ n.o(Zn) = +2

លេខរ៉ូម៉ាំង II តំណាងឲ្យចំនួនអុកស៊ីតកម្ម +2 របស់លោហៈ Zn ដែលមានក្នុង $[Zn(OH)_4]^{2-}$

ចំពោះកុំផ្លិចជាអាញ៉ុងវិញ ឈ្មោះរបស់លោហៈត្រូវបញ្ចប់ដោយ អាត។

នាំឲ្យឈ្មោះលោហៈស័ង្កសី ប្តូរជាឈ្មោះ**សាំងកាត**វិញ។

**ដូចនេះប៉ូតាស្យូមតេត្រាអ៊ីដ្រុកសូសាំងកាត(II)មានរូបមន្ត $K_2[Zn(OH)_4]$,**

ដឺតេរ្យូម (Deuterium), អ៊ីដ្រូសែន–2

អ៊ីយ៉ុងតេត្រាអាកូឌីអ៊ីដ្រុកសូ(III), $[Fe(H_2O)_4(OH)_2]^+$,

ការពន្យល់: លីកង់អាគូ (aquo) ត្រូវហៅឈ្មោះមុនលីកង់អ៊ីដ្រុកសូ (Hydroxo) ព្រោះហៅតាមអក្ខរក្រម

ដោយកុំផ្លិចជាកាចុងនោះផលបូកបន្ទុក (ចំនួនអុកស៊ីតកម្ម) សរុបស្មើបន្ទុករបស់វា យើងអាចសរសេរបាន:

n.o(Fe) + (0)4 +(–1)2 =+1 នាំឲ្យ n.o(Fe) = +2 ព្រោះ $H_2O$ ជាលីកង់ណឺត (neutral ligand) មានបន្ទុកស្មើសូន្យ និងបន្ទុករបស់អ៊ីដ្រុកសូស្មើ –1។

លេខរ៉ូម៉ាំង II តំណាងឲ្យចំនួនអុកស៊ីតកម្ម +2 របស់លោហៈដែកដែលមានក្នុង $[Fe(H_2O)_4(OH)_2]^+$

**ដូចនេះ** អ៊ីយ៉ុងតេត្រាអាកូឌីអ៊ីដ្រុកសូ(III) មានរូបមន្ត $[Fe(H_2O)_4(OH)_2]^+$,

ទ្រីចូម (Tritium), អ៊ីដ្រូសែន–3




របៀបហៅឈ្មោះអ៊ីសូតូម សរសេរឈ្មោះរបស់ធាតុដោយ

ភ្ជាប់ជាមួយសញ្ញា (–) និងម៉ាសអាតូម

ឧទាហរណ៍: ${}^{12}_{6}C$ កាបូន–12 ${}^{13}_{6}C$ កាបូន–13

${}^{14}_{6}C$ កាបូន–14

${}^{35}_{17}Cl$ ក្លរ–35 ${}^{37}_{17}Cl$ ក្លរ–37

${}^{59}_{28}Ni$ នីកែល–59 ${}^{18}_{8}O$ អុកស៊ីសែន–18 ${}^{17}_{8}O$ អុកស៊ីសែន–17 ${}^{16}_{8}O$ អុកស៊ីសែន–16

ឌីអាសូតប៉ង់តុកស៊ីត,

បារត(I)អ៊ីយ៉ូឌួ, អាស៊ីតក្រូមិច, ឌីក្លអិបតុកស៊ីត

អ៊ីសូតូប: ជាអាតូមដែលមានលេខលំដាប់ ឬ លេខអាតូមដូចគ្នាប៉ុន្តែចំនួនម៉ាសខុសគ្នា។

ឧទាហរណ៍: ${}^{12}_{6}C$, ${}^{13}_{6}C$, ${}^{14}_{6}C$ ជាអ៊ីសូតូបនឹងគ្នាព្រោះមានលេខលំដាប់ ឬ លេខអាតូមដូចគ្នា (Z = 6)។

អ៊ីសូមែ: ជាម៉ូលេគុលដែលមានរូបមន្តដុលឬ រូបមន្តម៉ូលេគុលដូចគ្នាប៉ុន្តែមានរូបមន្តស្នើលាតខុសគ្នា។

ឧទាហរណ៍: $CH_3$-$CH_2$-OH និង $CH_3$-O-$CH_3$ ជាអ៊ីសូមែនឹងគ្នា ព្រោះមានរូបមន្តដុលដូចគ្នា ($C_2H_6O$)។

អ៊ីសូអេឡិចត្រូនិច: ជាអាតូម ឬ អ៊ីយ៉ុងដែលមានចំនួនអេឡិចត្រុងដូចគ្នា មានរបាយអេឡិចត្រុងដូចគ្នា។ ឧទាហរណ៍: $N^{3-}$, $F^-$ និង Ne ជាអ៊ីសូអេឡិចត្រូនិចនឹងគ្នា (មាន 10 អេឡិចត្រុងដូចគ្នា)។

II. ក. ចូរសរសេររបាយអេឡិចត្រុងនៃអាតូម និង អ៊ីយ៉ុងនីមួយៗដូចតទៅ:

Fe (Z = 26): [Ar] $4s^2 3d^6$ មានអេឡិចត្រុងសេរីសរុប 4,




$Fe^{2+}$: [Ar] $4s^0 3d^6$ មានអេឡិចត្រុងសេរីសរុប 4

$Ni^{2+}$ (Z = 28): [Ar] $3d^8$ មានអេឡិចត្រុងសេរីសរុប 2,

$Cu^{2+}$ (Z = 29): [Ar] $3d^9$ មានអេឡិចត្រុងសេរីសរុប 1,

$Pt^{2+}$ (Z = 78): [Xe] $4f^{14}$ $5d^8$ មានអេឡិចត្រុងសេរីសរុប 2,

$Pt^{4+}$: [Xe] $4f^{14}$ $5d^6$ មានអេឡិចត្រុងសេរីសរុប 4,

Co (Z = 27): [Ar] $4s^2 3d^7$ មានអេឡិចត្រុងសេរីសរុប 3,

គ្មានអាតូម និង អ៊ីយ៉ុងខាងលើនេះជាដ្យាម៉ាញ៉េទិចទេ។

$Ni^{2+}$ and Fe (26 $e^-$), $Cu^{2+}$ and Co (27 $e^-$) ជាអ៊ីសូអេឡិចត្រូនិចនឹងគ្នា។

III. ក. យើងមាន: 1 mol អាតូម X = $6.022 \times 10^{23}$ អាតូម X = $N_A$ អាតូម X

1mol អាតូម X = M (g) អាតូម X នោះយើងបាន: M (g) អាតូម X = $N_A$ អាតូម X

នាំឲ្យ: ម៉ាស 1 អាតូម X = $\frac{M\ (g) \text{ អាតូម } X}{N_A \text{ អាតូម } X}$ (1)

ប៉ុន្តែ A = ចំនួនប្រូតុង + ចំនួនណឺត្រុង = Z + N

នាំឲ្យម៉ាស 1 អាតូម X = $Z \times m_p + N \times m_n = m_p (Z + N) = m_p \times A = 1.67 \times 10^{-24}$ g x A (2)

ព្រោះម៉ាស 1 ប្រូតុង = ម៉ាស 1 ណឺត្រុង = $1.67 \times 10^{-24}$ g

តាម (1) និង (2) យើងបាន: $\frac{M\ (g)\ \text{អាតូម X}}{N_A\ \text{អាតូម X}} = 1.67 \times 10^{-24} \times A$

នាំឲ្យ $M(X) = 1.67 \times 10^{-24} \times A \times N_A = 1 / N_A \times A \times N_A = A$ (g/mol)

ដោយ $1 / N_A \approx 1.67 \times 10^{-24}$ ដូចនេះ $M \approx A$ (g/mol)

ខ. យើងមាន 1mol អាតូមកាបូន -12 = 12g អាតូមកាបូន -12

1mol អាតូមកាបូន -12 = $6.022 \times 10^{23}$ អាតូមកាបូន -12 = $N_A$ អាតូមកាបូន -12

នោះយើងបាន: 12 g អាតូមកាបូន -12 = $N_A$ អាតូមកាបូន -12

នាំឲ្យ: ម៉ាស 1 អាតូមកាបូន -12 = $\frac{12\ g\ \text{អាតូមកាបូន} -12}{N_A\ \text{អាតូមកាបូន} -12}$

ប៉ុន្តែ ម៉ាស 1 អាតូមកាបូន -12 = 12 amu

យើងបាន: 12 amu = $\frac{12\ g\ \text{អាតូមកាបូន} -12}{N_A\ \text{អាតូមកាបូន} -12}$ នាំឲ្យ 1 g = $N_A$ amu = $6.022 \times 10^{23}$ amu

ដូចនេះ 1 g = $N_A$ amu = $6.022 \times 10^{23}$ amu ឬ 1 amu = $1.661 \times 10^{-24}$ g

តើ $3.01 \times 10^{23}$ amu មានប៉ុន្មានក្រាម? តើ 8.4 g មានប៉ុន្មាន amu?

យើងមាន 1 g = $N_A$ amu = $6.022 \times 10^{23}$ amu

ដូចនេះ $3.01 \times 10^{23}$ amu = $3.01 \times 10^{23}$ amu $\times \frac{1\ g}{6.022 \times 10^{23}} = 0.5$ g

ដូចនេះ 8.4 g = 8.4 g $\times \frac{6.022 \times 10^{23}}{1\ g} = 5.1 \times 10^{24}$ amu

IV. គណនាប៉ូតង់ស្យែលអេឡិចត្រូតនៃកន្លះពិលនីមួយៗ និង គណនាកម្លាំងអគ្គីសនីចលកនៃថ្មពិល

វិធីទី១ សមីការកន្លះពិលទីមួយ

$MnO_4^-\ (aq) + 8\ H^+\ (aq) + 5\ e^- \rightarrow Mn^{2+}\ (aq) + 4\ H_2O\ (l)$ $E^o = 1.51$ V

$$Q = \frac{[Mn^{2+}]}{[MnO_4^-] \times [H^+]^8}$$ ដែល $[MnO_4^-] = 0.1$ M និង $[Mn^{2+}] = 0.2$ M

$[H^+] = 0.1$ M

នោះយើងបាន $Q = \frac{0.2}{(0.1)(0.1)^8} = 2 \times 10^8$

តាមសមីការ $E = E^o - \frac{0.0592\ V}{n} \log Q$

នោះយើងបាន $E = 1.51\ V - \frac{0.0592\ V}{5} \log 2 \times 10^8$ ដែល E = 1.51 V និង n = 5

យើងបាន E = 1.51 V – 0.098 V = 1.412 V

សមីការកន្លះពិលទីពីរ

$Cr_2O_7^{2-}$ (aq) + 14 $H^+$ (aq) + 6 $e^-$ → 2 $Cr^{3+}$ (aq) + 7 $H_2O$ (l) $E^o = 1.33$ V

$$Q = \frac{[Cr^{3+}]^2}{[Cr_2O_7^{2-}] \times [H^+]^{14}}$$ ដែល $[Cr_2O_7^{2-}] = 0.1$ M និង $[Cr^{3+}] = 0.2$ M

$[H^+] = 0.1$ M

នោះយើងបាន $Q = \frac{(0.2)^2}{(0.1)(0.1)^{14}} = 4 \times 10^{13}$

តាមសមីការ $E = E^o - \frac{0.0592\ V}{n} \log Q$

នោះយើងបាន $E = 1.33\ V - \frac{0.0592\ V}{6} \log 4 \times 10^{13}$ ដែល E = 1.33 V និង n = 6

យើងបាន E = 1.33 V – 0.134 V = 1.196 V

ដូចនេះកម្លាំងអគ្គីសនីចលកនៃថ្មពិលនេះស្មើ 1.412 V – 1.196 V = 0.216 V

**វិធីទី២** សមីការកន្លះពិលទីមួយ

$MnO_4^-$ (aq) + 8 $H^+$ (aq) + 5 $e^-$ → $Mn^{2+}$ (aq) + 4 $H_2O$ (l) $E^o = 1.51$ V

$Q = \frac{[Mn^{2+}]}{[MnO_4^-] \times [H^+]^8}$ ដែល $[MnO_4^-] = 0.1$ M និង $[Mn^{2+}] = 0.2$ M

$[H^+] = 0.1$ M

នោះយើងបាន $Q = \frac{0.2}{(0.1)(0.1)^8} = 2 \times 10^8$

តាមសមីការ $E = E^o - \frac{0.0257\ V}{n} \ln Q$

នោះយើងបាន $E = 1.51\ V - \frac{0.0257\ V}{5} \ln 2 \times 10^8$ ដែល E = 1.51 V និង n = 5

យើងបាន E = 1.51 V – 0.098 V = 1.412 V

សមីការកន្លះពិលទីពីរ

$Cr_2O_7^{2-}$ (aq) + 14 $H^+$ (aq) + 6 $e^-$ → 2 $Cr^{3+}$ (aq) + 7 $H_2O$ (l) $E^o = 1.33$ V

$Q = \frac{[Cr^{3+}]^2}{[Cr_2O_7^{2-}] \times [H^+]^{14}}$ ដែល $[Cr_2O_7^{2-}] = 0.1$ M និង $[Cr^{3+}] = 0.2$ M

$[H^+] = 0.1$ M

នោះយើងបាន $Q = \frac{(0.2)^2}{(0.1)(0.1)^{14}} = 4 \times 10^{13}$

តាមសមីការ $E = E^o - \frac{0.0257\ V}{n} \ln Q$

នោះយើងបាន $E = 1.33\ V - \frac{0.0257\ V}{6} \ln 4 \times 10^{13}$ ដែល E = 1.33 V និង n = 6

យើងបាន E = 1.33 V – 0.134 V = 1.196 V

ដូចនេះកម្លាំងអគ្គីសនីចលករនៃថ្មពិលនេះស្មើ 1.412 V – 1.196 V = 0.216 V

V.១. សរសេរសមីការនៃប្រតិកម្មបំបែកអ៊ីដ្រូសែនពែអុកស៊ីត ទៅជាឧស្ម័នអុកស៊ីសែន និង ទឹក

2 $H_2O_2$ → 2 $H_2O$ + $O_2$

២. តើតម្លៃរយៈពេល (នាទី) ពាក់កណ្ដាលប្រតិកម្មបំបែកនេះស្មើប៉ុន្មាន?

តាមរូបមន្ត $t_{1/2} = \frac{\ln 2}{k} = \frac{0.693}{6.4 \times 10^{-5}\ s^{-1}} = 10828\ s = 180\ min$

ដូចនេះរយៈពេលពាក់កណ្ដាលប្រតិកម្ម $t_{1/2} = 180$ នាទី

៣. តើអ៊ីដ្រូសែនពែអុកស៊ីតបំបែកអស់ប៉ុន្មានភាគរយ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តអស់រយៈពេល 600 s

វិធីទី១ តាមរូបមន្ត $\ln\frac{[A]_t}{[A]_o} = -kt$ នាំឲ្យ $\frac{[A]_t}{[A]_o} = e^{-\left(\frac{\ln 2}{10828}\right)600} = e^{-0.0384} = 0.962$

នោះយើងបានអ៊ីដ្រូសែនពែអុកស៊ីតនៅសល់ 0.962 x 100 % = 96.2 %

ដូចនេះភាគរយអ៊ីដ្រូសែនពែអុកស៊ីតបំបែក = 100 % – 96.2 % = 3.80 %

វិធីទី២ តាមរូបមន្ត $\ln\frac{[A]_t}{[A]_o} = -kt = -\frac{\ln 2}{t_{\frac{1}{2}}} t = \ln 2^{\left(-\frac{t}{t_{\frac{1}{2}}}\right)}$

នាំឲ្យ $\frac{[A]_t}{[A]_o} = 2^{-\left(\frac{600}{10828}\right)} = 2^{-0.0554} = 0.962$

នោះយើងបានអ៊ីដ្រូសែនពែអុកស៊ីតនៅសល់ 0.962 x 100 % = 96.2 %

ដូចនេះភាគរយអ៊ីដ្រូសែនពែអុកស៊ីតបំបែក = 100 % – 96.2 % = 3.80 %

៤. តើអ៊ីដ្រូសែនពែអុកស៊ីតបំបែកអស់ប៉ុន្មានភាគរយ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តអស់រយៈពេល 450 s

វិធីទី១ តាមរូបមន្ត $\ln\frac{[A]_t}{[A]_o} = -kt$ នាំឲ្យ $\frac{[A]_t}{[A]_o} = e^{-\left(\frac{\ln 2}{10828}\right)450} = e^{-0.0288} = 0.972$

នោះយើងបានអ៊ីដ្រូសែនពែអុកស៊ីតនៅសល់ 0.972 x 100 % = 97.2 %

ដូចនេះភាគរយអ៊ីដ្រូសែនពែអុកស៊ីតបំបែក = 100 % – 97.2 % = 2.80 %

វិធីទី២ តាមរូបមន្ត $\ln\frac{[A]_t}{[A]_o} = -kt = -\frac{\ln 2}{t_{\frac{1}{2}}} t = \ln 2^{\left(-\frac{t}{t_{\frac{1}{2}}}\right)}$

នាំឲ្យ $\frac{[A]_t}{[A]_o} = 2^{-\left(\frac{450}{10828}\right)} = 2^{-0.0416} = 0.972$

នោះយើងបានអ៊ីដ្រូសែនពែអុកស៊ីតនៅសល់ $0.972 \times 100\ \% = 97.2\ \%$

ដូចនេះភាគរយអ៊ីដ្រូសែនពែអុកស៊ីតបំបែក $= 100\ \% - 97.2\ \% = 2.80\ \%$

៥. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីឲ្យអ៊ីដ្រូសែនពែអុកស៊ីតសល់ 5 %?

**វិធីទី១** តាមរូបមន្ត $\ln\frac{[A]_0}{[A]_t} = kt$ នាំឲ្យ $t = \frac{1}{k} \times \ln\frac{[A]_0}{[A]_t}$

យើងមានសមាសធាតុអ៊ីដ្រូសែនពែអុកស៊ីតដើម 100 % សមាសធាតុនេះបាននៅសល់ 5 % ដូចនេះ

ផលធៀបភាគរយស្មើផលធៀបកំហាប់ $\frac{[A]_0}{[A]_t} = \frac{100}{5} = 20$

យើងបាន $t = \frac{1}{6.4 \times 10^{-5}\ s^{-1}} \times \ln 20$

$= \frac{1}{6.4 \times 10^{-5}\ s^{-1}} \times (2\ln 2 + \ln 5) = 46797\ s = 780$ នាទី

ដូចនេះរយៈពេលដែលត្រូវការ $t = 780$ min

**វិធីទី២** តាមរូបមន្ត $\ln\frac{[A]_t}{[A]_o} = -kt$ នាំឲ្យ $t = -\frac{1}{k} \times \ln\frac{[A]_t}{[A]_o}$

យើងមានសមាសធាតុអ៊ីដ្រូសែនពែអុកស៊ីតដើម 100 % សមាសធាតុនេះបាននៅសល់ 5 % ដូចនេះ

ផលធៀបភាគរយស្មើផលធៀបកំហាប់ $\frac{[A]_t}{[A]_o} = \frac{5}{100} = 0.05$

យើងបាន $t = -\frac{1}{6.4 \times 10^{-5}\ s^{-1}} \times \ln 5\times10^{-2}$

$= -\frac{1}{6.4 \times 10^{-5}\ s^{-1}} \times (\ln 5 + \ln 10^{-2}) = 46808\ s = 780$ នាទី

ដូចនេះរយៈពេលដែលត្រូវការ $t = 780$ min

VI. ១. ក. សរសេរសមីការតាងប្រតិកម្មគីមីដែលបង្កើតកករក្យូម (III) អ៊ីយ៉ូឌួក្នុងសូលុយស្យុងនេះ

$Th^{3+}$ (aq) + 3 $I^-$ (aq) → $ThI_3$ (s)

ខ. គណនាមាឌសូលុយស្យុងសូដ្យូមអ៊ីយ៉ូឌួដែលចាំបាច់ត្រូវប្រើ

តាមរូបមន្ត $C_M = [NaI] = \frac{n_{NaI}}{V_{NaI}}$ នាំឲ្យ $V_{NaI} = \frac{n_{NaI}}{[NaI]}$

ដោយតាមសមីការ $n_{NaI} = 3 \times n\left(Th^{3+}\right) = 3\left(\frac{0.567\ g}{232\ g/mol}\right) = 7.33 \times 10^{-3}$ mol

យើងបាន $V_{NaI} = \frac{7.33 \times 10^{-3}\ mol}{0.5\ mol/L} = 14.66 \times 10^{-3}\ L = 14.66\ mL$

ដូចនេះមាឌសូលុយស្យុងសូដ្យូមអ៊ីយ៉ូឌួដែលចាំបាច់ត្រូវប្រើ $V_{NaI} = 14.66$ mL

២. សរសេរសមីការតាងប្រតិកម្មគីមី

$ThO_2$ (s) + 4 HCl (aq) → $ThCl_4$ (aq) + 2 $H_2O$ (l)

គណនាមាឌសូលុយស្យុងអាស៊ីតក្លរីឌ្រិចចាំបាច់ត្រូវប្រើ

តាមរូបមន្ត $C_M = [HCl] = \frac{n_{HCl}}{V_{HCl}}$ នាំឲ្យ $V_{HCl} = \frac{n_{HCl}}{[HCl]}$

ដោយតាមសមីការ $n_{HCl} = 4 \times n\left(ThO_2\right) = 4\left(\frac{10.56\ g}{264\ g/mol}\right) = 0.16$ mol

យើងបាន $V_{HCl} = \frac{0.16\ mol}{1.55\ mol/L} = 0.103\ L = 103\ mL$

ដូចនេះមាឌសូលុយស្យុងអាស៊ីតក្លរីឌ្រិចដែលចាំបាច់ត្រូវប្រើ $V_{HCl}$ = 103 mL

**រូបមន្តកំហាប់ជាម៉ូល**

$C_M = \frac{n}{V_S}$

នាំឲ្យ $V_S = \frac{n}{C_M}$

ខ្ញុំចែករំលែកឬក៏ដាក់ទានមិនមែនមានន័យថាខ្ញុំមានហូរហៀរនោះទេ ហើយកុំគិតថាខ្ញុំជាអ្នកមាន គ្រាន់តែខ្ញុំយល់ច្បាស់ពីអារម្មណ៍អ្នកអត់តែប៉ុណ្ណោះ

All rights reserved.

Prepared by Houn Kimsrea

May 25, 2018

## ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី............

វិញ្ញាសា គីមីទី ៣៣

រៀបរៀង ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០១៧

## វិញ្ញាសាៈ ឯកទេសទី១ គីមីវិទ្យា រយៈពេល ៣ ម៉ោង

ឈ្មោះ.................................លេខបន្ទប់...............លេខតុ.................ហត្ថលេខា.................

សម្រាប់និស្សិតគីមីត្រៀមប្រលង NIE Tel: 098 472 472

## ប្រធានវិញ្ញាសាគីមីវិទ្យាទី ៣៣

១. មានសិស្សម្នាក់ចង់ធ្វើសូលុយស្យុងអំបិល NaCl កំហាប់ 35 %។ តើអ្នកអាចជួយសិស្សដើម្បីធ្វើសូលុយស្យុងនេះបានដែរឬទេ? ចូរពន្យល់ចម្លើយរបស់អ្នក។ (២៩ ខែកញ្ញា ឆ្នាំ ២០១៣)

២. ក. ឧបមាថាក្នុងជើងបិទជិតមួយមានផ្ទុកឧស្ម័នពីរ A និង B នៅសីតុណ្ហភាពជាក់លាក់មួយ។ យើងអាចគណនារកសម្ពាធដោយផ្នែកនៃឧស្ម័ននីមួយៗបានដោយប្រើ ច្បាប់សម្ពាធដោយផ្នែករបស់ដាល់តុន ។ តើ សម្ពាធដោយផ្នែក និង ច្បាប់សម្ពាធដោយផ្នែករបស់ដាល់តុនមានន័យដូចម្តេច? ចូរទាញរកកន្សោមសម្ពាធដោយផ្នែកនៃឧស្ម័ន A និង B ជាអនុគមន៍សម្ពាធសរុប។

ខ. ចូរបង្ហាញពីទំនាក់ទំនងរវាង $K_C$ និង $K_P$ សម្រាប់ប្រតិកម្ម $a\,A(g) \rightleftharpoons b\,B(g)$

៣. គេមាននុយក្លេអ៊ូទីតនៃធាតុគីមីមួយតាងដោយនិមិត្តសញ្ញា $^{55}_{25}Mn^{2+}$។

ក. តើ $Mn^{2+}$ មានចំនួនអេឡិចត្រុងសរុបប៉ុន្មានក្នុងអ័រប៊ីតាល់ s ទាំងអស់ប៉ុន្មាន? ចូរបញ្ជាក់ដោយសរសេររបាយអេឡិចត្រុងតាមស្រទាប់នីមួយៗ។

ខ. តើមានចំនួនអេឡិចត្រុង ប្រូតុង និង ណឺត្រុងប៉ុន្មានដែលមានក្នុងអ៊ីយ៉ុង $Mn^{2+}$?

គ. តើមានម៉ាសអេឡិចត្រុង ប្រូតុង និង ណឺត្រុងប៉ុន្មានក្រាមដែលមានក្នុងអ៊ីយ៉ុង $Mn^{2+}$?

ឃ. តើអ៊ីយ៉ុង $Mn^{2+}$ ជាប្រភេទប៉ារ៉ាម៉ាញ៉េទិច ឬ ដ្យាម៉ាញ៉េទិច? ហេតុអ្វី?

ដោយសន្មត់ថាម៉ាស 1 ប្រូតុង = ម៉ាស 1 ណឺត្រុង = $1.67 \times 10^{-27}$ kg និង ម៉ាស 1 អេឡិចត្រុង = $9.11 \times 10^{-31}$ kg

៤. ល្បាយអង្គធាតុរឹង 3.459 g នៃអំបិល NaCl និង NaBr ត្រូវបានរំលាយក្នុងទឹករួចឲ្យប្រតិកម្មជាមួយសូលុយស្យុង $AgNO_3$ លើសគេទទួលបានសមាសធាតុកករ ។ កករដែលទទួលបានទាំងអស់ត្រូវបានយកទៅរំលាយដោយសូ

លុយស្យុង KCN ហើយសូលុយស្យុងដែលទទួលបានគេយកទៅធ្វើអគ្គីសនីវិភាគបន្តក្នុងមជ្ឈដ្ឋាន KOH។ ក្រោយអគ្គីសនីវិភាគចប់ គេទទួលបានអង្គធាតុរឹងសុទ្ធចំនួន 5.40 g។

ក. ចូរសរសេរសមីការតាងប្រតិកម្មគីមីតាមលំដាប់លំដោយនៃប្រព្រឹត្តកម្មខាងលើ។

ខ. គណនាភាគរយនៃអំបិលនីមួយៗក្នុងល្បាយដើម។ (២៨ ខែកញ្ញា ឆ្នាំ ២០១២)

(គេឲ្យម៉ាសអាតូមធៀប: Na = 23; Cl = 35.5; Br = 80; Ag = 108)

៥. ក. ពិលអេឡិចត្រូគីមីមួយបង្កដោយតួរេដុក និង មានកម្លាំងអគ្គិសនីចលករ E = 0.54 V នៅសីតុណ្ហភាព 25 °C ។ យើងសន្មត់ឲ្យ $[Zn^{2+}]$ = 1 M និង សម្ពាធអ៊ីដ្រូសែនស្មើ 1 atm។ (២០ ខែតុលា ឆ្នាំ ២០០៥)

ចូរគណនាកំហាប់ជាម៉ូលរបស់ $[H^+]$ និង pH ។ គេឲ្យ: ($\log 2 = 0.3$, $\ln X = -8.6 \rightarrow X = 2 \times 10^{-4}$)

ខ. ចូរព្យាករណ៍មើលថាតើប្រតិកម្មខាងក្រោមនេះអាចកើតឡើងបានដែរឬទេនៅសីតុណ្ហភាព 298 K

$$Co\,(s) + Fe^{2+}\,(aq) \rightarrow Co^{2+}\,(aq) + Fe\,(s)$$

គណនាថេរលំនឹង និង បម្រែបម្រួលថាមពលសេរីសម្រាប់ប្រតិកម្មនេះ។ (០១ ខែវិច្ឆិកា ឆ្នាំ ២០០៧)

គេឲ្យ: $E^o\,(Zn^{2+}/Zn) = -0.76$ V $E^o\,(Co^{2+}/Co) = -0.28$ V, $E^o\,(Fe^{2+}/Fe) = -0.44$V, $\ln X = -12.45 \rightarrow X = 4 \times 10^{-6}$

៦. ប្រតិកម្មបំបែកស៊ុលផួរីលក្លរ ($SO_2Cl_2$) ទៅជាស្ពាន់ធ័រឌីអុកស៊ីត និង ឧស្ម័នក្លរ គឺជាប្រតិកម្មលំដាប់១ ដែលមានរយៈពេលពាក់កណ្ដាលប្រតិកម្មស្មើ 8 នាទី។ (គេឲ្យ: $\ln 2 = 0.693$; $\ln 5 = 1.609$)

ក. គណនាតម្លៃថេរល្បឿននៃប្រតិកម្មនេះ (០៥ ខែតុលា ឆ្នាំ ២០១៦)

ខ. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីឲ្យស៊ុលផួរីលក្លរសល់ 1 % នៃបរិមាណដើម?

៧. សូលុយស្យុងទឹកអ៊ីយ៉ូដមួយមានមាឌ 25 mL មានអ៊ីយ៉ូតរលាយក្នុងនោះ 2 mg។ គេបន្ថែម 5 mL នៃសារធាតុរំលាយ $CCl_4$ ចូលដើម្បីដំណើរការញែកយកធាតុអ៊ីយ៉ូដចេញពីសូលុយស្យុងទឹកនោះ។ គេដឹងថាអ៊ីយ៉ូដអាចរលាយចូលអង្គធាតុរំលាយ $CCl_4$ បាន 85 ដងច្រើនជាងរលាយចូលក្នុងទឹកនៅលក្ខខណ្ឌពិសោធ។

ក. បន្ទាប់ពីការញែក តើម៉ាសអ៊ីយ៉ូដនៅសល់ក្នុងផាសទឹកប៉ុន្មាន mg? (២៨ ខែកញ្ញា ឆ្នាំ ២០១២)

ខ. បើគេញែកវាជាលើកទីពីរដោយប្រើ $CCl_4$ 5 mL ថ្មីទៀតតើម៉ាសអ៊ីយ៉ូដប៉ុន្មាននឹងនៅសល់ក្នុងផាសទឹក?

ចម្លើយប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី............

វិញ្ញាសា គីមីទី ៣៣

រៀបរៀង ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០១៧

វិញ្ញាសាៈ ឯកទេសទី១ គីមីវិទ្យា រយៈពេល ៣ ម៉ោង

ឈ្មោះ..................................លេខបន្ទប់...............លេខតុ.................ហត្ថលេខា.................

(សម្រាប់និស្សិតគីមីត្រៀមប្រលង NIE) Tel: 098 472 472

## ដំណោះស្រាយវិញ្ញាសាគីមីវិទ្យា

១. យើងមិនអាចជួយសិស្សដើម្បីធ្វើសូលុយស្យុងអំបិល NaCl កំហាប់ 35 % បានទេ ព្រោះកម្រិតរលាយសូដ្យូមក្លរួអតិបរិមាក្នុងទឹកប្រហែល 39 g / 100 mL នៅសីតុណ្ហភាព 20 ºC ។ ទោះបីសីតុណ្ហភាពលើសពីនេះក៏ដោយ កម្រិតរលាយសូដ្យូមក្លរួអតិបរិមាក្នុងទឹកប្រហែល 39 g / 100 mL ដែរ។

យើងបាន ម៉ាស NaCl = 39 g និង ម៉ាសសូលុយស្យុងអំបិល NaCl = 100 g + 39 g = 139 g

$$\% \text{ NaCl} = \frac{39\text{ g}}{139\text{ g}} \times 100 = 28\ \%$$

ដូចនេះ យើងមិនអាចជួយសិស្សដើម្បីធ្វើសូលុយស្យុងអំបិល NaCl កំហាប់ 35 % បានទេ។

២. ក. សម្ពាធដោយផ្នែក គឺជាសម្ពាធនៃឧស្ម័ននីមួយៗដែលមានក្នុងល្បាយ។

ខ. ច្បាប់សម្ពាធដោយផ្នែករបស់ដាល់តុនមានន័យថា សម្ពាធសរុបនៃល្បាយឧស្ម័ន គឺជាផលបូកសម្ពាធ នៃឧស្ម័ននីមួយៗដែលមានក្នុងល្បាយ។ ឧបមាថាក្នុងជើងបិទជិតមួយមានផ្ទុកឧស្ម័នពីរ A និង B នោះ សម្ពាធឧស្ម័ន A និង B ជាសម្ពាធដោយផ្នែក។

យើងមានសម្ពាធដោយផ្នែកឧស្ម័ន A: $P_A = (n_A \frac{RT}{V})$

សម្ពាធដោយផ្នែកឧស្ម័ន B: $P_B = (n_B \frac{RT}{V})$

នោះសម្ពាធសរុបល្បាយឧស្ម័ន: $P_{សរុប} = P_A + P_B = (n_A \frac{RT}{V}) + (n_B \frac{RT}{V}) = \frac{RT}{V}(n_A + n_B) = \frac{nRT}{V}$

ដែល $n = n_A + n_B$

យកសម្ពាធដោយផ្នែកឧស្ម័ន A ធៀបនឹងសម្ពាធសរុបយើងបាន

$$\frac{P_A}{P_T} = \frac{n_A RT/V}{(n_A+n_B)RT/V} = \frac{n_A}{n_A+n_B} = X_A,\ \text{ដែល}\ \frac{n_A}{n_A+n_B} = X_A$$ ជាប្រភាគម៉ូលឧស្ម័ន A

ដូចនេះយើងបាន $P_A = X_A \times P_{សរុប}$

នាំឲ្យ: $P_B = P_{សរុប} - P_A = P_{សរុប} - X_A \times P_{សរុប} = P_{សរុប}(1 - X_A) = X_B \times P_{សរុប}$

(ព្រោះ $X_A + X_B = \frac{n_A}{n_A+n_B} + \frac{n_B}{n_A+n_B} = \frac{n_A+n_B}{n_A+n_B} = 1$)

ដូចនេះយើងបាន $P_B = X_B \times P_{សរុប}$ ដែល $X_B = 1 - X_A$ ជាប្រភាគម៉ូលឧស្ម័ន B

ខ. យើងមានសម្ពាធដោយផ្នែកឧស្ម័ន A: $P_A = (n_A \frac{RT}{V})$

សម្ពាធដោយផ្នែកឧស្ម័ន B: $P_B = (n_B \frac{RT}{V})$ និង ថេរលំនឹង $K_c = \frac{[B]^b}{[A]^a}$

តែ $$K_p = \frac{P_B^b}{P_A^a} = \frac{\left(\frac{n_B RT}{V}\right)^b}{\left(\frac{n_A RT}{V}\right)^a} = \frac{\left(\frac{n_B}{V}\right)^b}{\left(\frac{n_A}{V}\right)^a}(RT)^{b-a} = \frac{[B]^b}{[A]^a}(RT)^{\Delta n} = K_C (RT)^{\Delta n}$$

ព្រោះ $\Delta n$ = ចំនួនម៉ូលឧស្ម័នអង្គធាតុកកើត – ចំនួនម៉ូលឧស្ម័នអង្គធាតុប្រតិករ = b – a

ដូចនេះទំនាក់ទំនងរវាង $K_C$ និង $K_P$ គឺ $K_P = K_C (RT)^{\Delta n}$

៣. ក. អ៊ីយ៉ុង $Mn^{2+}$ មានចំនួនអេឡិចត្រុងសរុបក្នុងអ័រប៊ីតាល់ s ទាំងអស់ 6។

សរសេរបាយអេឡិចត្រុងតាមស្រទាប់នីមួយៗ $1s^2 2s^2 2p^6 3s^2 3p^6 4s^0 3d^5$

ខ. អ៊ីយ៉ុង $Mn^{2+}$ មាន 25 ប្រូតុង 30 ណឺត្រុង និង 23 អេឡិចត្រុង។

គ. តើមានម៉ាសអេឡិចត្រុង ប្រូតុង និង ណឺត្រុងប៉ុន្មានក្រាមដែលមានក្នុងអ៊ីយ៉ុង $Mn^{2+}$?

ម៉ាស 1 ប្រូតុង = ម៉ាស 1 ណឺត្រុង = $1.67\times10^{-27}$ kg និង ម៉ាសម៉ាស 1 អេឡិចត្រុង = $9.11\times10^{-31}$ kg

យើងបាន: ម៉ាសអេឡិចត្រុង = $23 \times 9.11\times10^{-31}$ kg = $2.1 \times 10^{-29}$ kg = $2.1 \times 10^{-26}$ g

ម៉ាសប្រូតុង = 25 x $1.67 \times 10^{-27}$ kg = $4.2 \times 10^{-26}$ kg = $4.2 \times 10^{-23}$ g

ម៉ាសណឺត្រុង = 30 x $1.67 \times 10^{-27}$ kg = $5.0 \times 10^{-26}$ kg = $5.0 \times 10^{-23}$ g

ឃ. អ៊ីយ៉ុង $Mn^{2+}$ ជាប្រភេទប៉ារ៉ាម៉ាញ៉េទិច ព្រោះវាមានអេឡិចត្រុងសេរីចំនួន 5 ស្រទាប់រង 3 $d^5$។

៤. ក. សរសេរសមីការតាងប្រតិកម្មគីមីតាមលំដាប់លំដោយនៃប្រព្រឹត្តកម្មខាងលើ

$$NaCl + AgNO_3 \rightarrow AgCl + NaNO_3$$

$$NaBr + AgNO_3 \rightarrow AgBr + NaNO_3$$

$$AgCl + 2\,KCN \rightarrow K[Ag(CN)_2] + KCl$$

$$AgBr + 2\,KCN \rightarrow K[Ag(CN)_2] + KBr$$

$$4\,K[Ag(CN)_2] + 4\,KOH \rightarrow 4\,Ag + 8\,KCN + O_2 + 2\,H_2O$$

ខ. គណនាភាគរយនៃអំបិលនីមួយៗក្នុងល្បាយដើម

**វិធីទី១៖** តាង X ជាម៉ាស NaCl នោះយើងបាន 3.459 g – X ជាម៉ាស NaBr

តាមសមីការខាងលើយើងបាន n (NaCl) + n (NaBr) = n (Ag)

ដោយ M (NaCl) = 58.5 g/mol , M (NaBr) = 103 g/mol , M (Ag) = 108 g/mol

យើងបាន $\frac{X}{58.5} + \frac{3.459 - X}{103} = \frac{5.4}{108} = 0.05$ mol

យើងបាន X = m (NaCl) = 2.223 g នោះ m (NaBr) = 3.459 g – 2.223 g = 1.236 g

ដូចនេះយើងបាន % NaCl = $\frac{2.223\text{ g}}{3.459\text{ g}} \times 100\,\% = 64.27\,\%$

នោះ % NaBr = 100 % –% NaCl = 100 % – 64.27% = 35.73 %

ឬ % NaBr = $\frac{1.236\text{ g}}{3.459\text{ g}} \times 100\,\% = 35.73\,\%$

**វិធីទី២៖** តាង X ជាចំនួនម៉ូល NaCl និង Y ជាចំនួនម៉ូល NaBr

តាមសមីការខាងលើយើងបាន n (NaCl) + n (NaBr) = n (Ag)

**Let X is mass of NaCl,**
**then, mass of NaBr = 3.5 –X**

**Let X is mass of NaCl,**
**then, mass of NaBr = 3.5 –X**

% NaCl = $\frac{m_{NaCl}}{\text{mass of mixture}} \times 100$

% NaBr = $\frac{m_{NaBr}}{\text{mass of mixture}} \times 100$

% NaCl + % NaBr = 100 %

Then, % NaBr = 100 % – %NaCl

% NaCl = 100 % – %NaBr

ដោយ M (NaCl) = 58.5 g/mol , M (NaBr) = 103 g/mol , M (Ag) = 108 g/mol

នោះ X + Y = 0.05 mol

58.5 X + 103 Y = 3.459

យើងបាន X = n (NaCl) = 0.038 mol និង Y = n (NaBr) = 0.012 mol

នោះយើងបាន m (NaCl) = 0.038 mol x 58.5 g/mo = 2.223 g

m (NaBr) = 0.012 mol x 103 g/mol = 1.236 g ឬ m (NaBr) = 3.459 g – 2.223 g = 1.236 g

ដូចនេះយើងបាន % NaCl = $\frac{2.223 \text{ g}}{3.459 \text{ g}}$ x 100 % = 64.27 %

នោះ % NaBr = $\frac{1.236 \text{ g}}{3.459 \text{ g}}$ x 100 % = 35.73 %

ឬ % NaBr = 100 % – % NaCl = 100 % – 64.27 % = 35.73 %

**វិធីទី៣៖** តាង X ជាចំនួនម៉ូល NaCl នោះយើងបាន 3.459 g – 58.5 X ជាម៉ាស NaBr

តាមសមីការខាងលើយើងបាន n (NaCl) + n (NaBr) = n (Ag)

ដោយ M (NaCl) = 58.5 g/mol , M (NaBr) = 103 g/mol , M (Ag) = 108 g/mol

យើងបាន $X + \frac{3.459 - 58.5X}{103} = \frac{5.4}{108} = 0.05$ mol

នោះយើងបាន X = n (NaCl) = 0.038 mol នោះ m (NaCl) = 0.038 mol x 58.5 g/mol = 2.223 g

នោះ m (NaBr) = 3.459 g – 2.223 g = 1.236 g

ដូចនេះយើងបាន % NaCl = $\frac{2.223 \text{ g}}{3.459 \text{ g}}$ x 100 % = 64.27 %

នោះ % NaBr = 100 % – % NaCl = 100 % – 64.27 % = 35.73 %

ឬ % NaBr = $\frac{1.236 \text{ g}}{3.459 \text{ g}}$ x 100 % = 35.73 %

> Let X is mole of NaCl,
>
> M (NaCl) = 58.5 g/ mol
>
> Then m (NaCl) = 58.5 X
>
> m (NaBr) = 3.5 – 58.5 X
>
> n(NaBr) = $\frac{3.50 - 58.5X}{103}$

**វិធីទី៤៖** តាង X ជាចំនួនម៉ាស NaCl នោះយើងបាន $\frac{3.459 \text{ g} - X}{103}$ ជាម៉ូល NaBr

តាមសមីការខាងលើយើងបាន n (NaCl) + n (NaBr) = n (Ag)

ដោយ M (NaCl) = 58.5 g/mol , M (NaBr) = 103 g/mol , M (Ag) = 108 g/mol

យើងបាន $\frac{X}{58.5} + \frac{3.459 - X}{103} = \frac{5.4}{108} = 0.05$ mol

យើងបាន X = m (NaCl) = 2.223 g នោះ m (NaBr) = 3.459 g – 2.223 g = 1.236 g

ដូចនេះយើងបាន % NaCl = $\frac{2.223\text{ g}}{3.459\text{ g}}$ x 100 % = 64.27 %

នោះ % NaBr = 100 % – % NaCl = 100 % – 64.27 % = 35.73 %

ឬ % NaBr = $\frac{1.236\text{ g}}{3.459\text{ g}}$ x 100 % = 35.73 %

**វិធីទី៥៖** តាង X ជាចំនួនម៉ាស NaBr នោះយើងបាន $\frac{3.459\text{ g} - X}{58.5}$ ជាម៉ូល NaCl

Let X is mass of NaCl,

Then m (NaBr) = 3.5 – X

M(NaBr) = 103 g/mol, then

n (NaBr) = $\frac{3.5-X}{103}$

តាមសមីការខាងលើយើងបាន n (NaCl) + n (NaBr) = n (Ag)

ដោយ M (NaCl) = 58.5 g/mol , M (NaBr) = 103 g/mol , M (Ag) = 108 g/mol

យើងបាន $\frac{X}{103} + \frac{3.459 - X}{58.5} = \frac{5.4}{108} = 0.05$ mol

យើងបាន X = m (NaBr) = 1.236 g នោះ m (NaCl) = 3.459 g – 1.236g = 2.223 g

Let X is mass of NaBr,

Then m (NaCl) = 3.459 – X

M(NaCl) = 58.5 g/mol, then

n (NaBr) = $\frac{3.459-X}{58.5}$

ដូចនេះយើងបាន % NaCl = $\frac{2.223\text{ g}}{3.459\text{ g}}$ x 100 % = 64.27 %

នោះ % NaBr = 100 % – % NaCl = 100 % – 64.27 % = 35.73 %

ឬ % NaBr = $\frac{1.236\text{ g}}{3.459\text{ g}}$ x 100 % = 35.73 %

**វិធីទី៦៖** តាង X ជាចំនួនម៉ូល NaBr នោះយើងបាន 3.459g – 103X ជាម៉ាស NaCl

តាមសមីការខាងលើយើងបាន n (NaCl) + n (NaBr) = n (Ag)

ដោយ M (NaCl) = 58.5 g/mol , M (NaBr) = 103 g/mol , M (Ag) = 108 g/mol

យើងបាន $X + \frac{3.459 - 103\,X}{58.5} = \frac{5.4}{108} = 0.05$ mol

នោះយើងបាន X = n (NaBr) = 0.012 mol នោះ m (NaBr) = 0.038 mol x 103 g/mol = 1.236 g

នោះ m (NaCl) = 3.459 g – 1.236 g = 2.223 g

ដូចនេះយើងបាន $\% \text{ NaCl} = \frac{2.223\text{ g}}{3.459\text{ g}} \times 100\ \% = 64.27\ \%$

នោះ % NaBr = 100 % – % NaCl = 100 % – 64.27 % = 35.73 %

ឬ $\% \text{ NaBr} = \frac{1.236\text{ g}}{3.459\text{ g}} \times 100\ \% = 35.73\ \%$

Let X is mole of NaBr,

M (NaBr) = 103 g/ mol

Then m (NaBr) = 103 X

m (NaCl) = 3.459 – 103 X

$n(\text{NaCl}) = \frac{3.459 - 103\,X}{58.5}$

- ចំណាំ: ចូរព្យាយាមដោះស្រាយវិធីផ្សេងទៀតតាមសមត្ថភាពដែលអាចធ្វើបាន

៥. ក. គណនាកំហាប់ជាម៉ូលរបស់ $[H^+]$ និង pH

សមីការពាក់កណ្ដាលពិលនីមួយៗ

$2\,H^+ (aq) + 2\,e^- \rightarrow H_2 (g)$ (កាតូត)

$Zn (s) \rightarrow Zn^{2+} (aq) + 2\,e^-$ (អាណូត)

យើងបានសមីការតុល្យការ: $2\,H^+ (aq) + Zn (s) \rightarrow H_2 (g) + Zn^{2+} (aq)$

$\Delta E^0 = E^0$ (កាតូត) – $E^0$ (អាណូត) = 0.00 V – (– 0.76 V) = 0.76 V

$K = \frac{P(H_2)\,[Zn^{2+}]}{[H^+]^2} = \frac{1}{[Ag^+]^2}$ ដែល $[Zn^{2+}] = 1$ M និង $P(H_2) = 1$ atm

តាមសមីការ $E = E^0 - \frac{0.0257\text{ V}}{n} \ln K$ ដែល E = 0.54 V និង n = 2

យើងបាន $0.54\ V = 0.76\ V - \frac{0.0257\ V}{2} \ln \frac{1}{[H^+]^2}$

នោះ $\ln [H^+] = -8.6$ ដោយ $\ln X = -8.6$ នាំឲ្យ $X = 2 \times 10^{-4}$

ដូចនេះយើងបាន $[H^+] = 2 \times 10^{-4}$ M

តាមរូបមន្ត $pH = -\log [H^+] = -\log 2 \times 10^{-4} = 4 - \log 2 = 4 - 0.3 = 3.7$

**វិធីទី២៖** សមីការពាក់កណ្ដាលពិលនីមួយៗលំនាំរេដុកម្មនៃគូ $H_3O^+ / H_2$

$$2\ H_3O^+ (aq) + 2e^- \rightarrow H_2 (g) + 2\ H_2O (l) \qquad E^0 = 0.00\ V$$

តាមសមីការ $E = E^0 - \frac{0.0257\ V}{n} \ln K$ ដែល $E^\circ = 0.00$ V និង $n = 2$

ដោយ $K = \frac{1}{[H_3O^+]^2}$ ដែល $P (H_2) = 1$ atm

យើងបាន $E = 0.00\ V - \frac{0.0257\ V}{2} \ln \frac{1}{[H_3O^+]^2}$

$= 0.0257\ V \ln [H_3O^+]$

សមីការពាក់កណ្ដាលពិលនីមួយៗលំនាំរេដុកម្មនៃគូ $Zn^{2+} / Zn$

$$Zn^{2+} (aq) + 2\ e^- \rightarrow Zn (s) \qquad E^\circ = -0.76\ V$$

តាមសមីការ $E = E^0 - \frac{0.0257\ V}{n} \ln K$ ដែល $E^\circ = -0.76$ V និង $n = 2$, $[Zn^{2+}] = 1.00$ M

យើងបាន $E = -0.76\ V - \frac{0.0257\ V}{2} \ln \frac{1}{[Zn^{2+}]} = -0.76\ V$ ដោយ $K = \frac{1}{[Zn^{2+}]} = 1$

ដោយសមីការតុល្យការៈ $Zn (aq) + 2\ H^+ (aq) \rightarrow Zn^{2+} (aq) + H_2 (g)$

យើងបាន $\Delta E = E (H_3O^+ / H_2) - E (Zn^{2+} / Zn)$

$0.540\ V = 0.0257\ V \ln [H_3O^+] - (-0.76\ V)$

$0.54\ V = 0.0257\ V \ln [H_3O^+] + 0.76\ V$

នោះ $\ln [H_3O^+] = -8.6$ ដោយ $\ln X = -8.6$ នាំឲ្យ $X = 2 \times 10^{-4}$

ដូចនេះយើងបាន $[H^+] = 2 \times 10^{-4}$ M

តាមរូបមន្ត $pH = -\log[H^+] = -\log 2 \times 10^{-4} = 4 - \log 2 = 4 - 0.3 = 3.7$

ខ. ប្រតិកម្មនេះមិនអាចកើតឡើងបានទេនៅសីតុណ្ហភាព 298 K។

គណនាថេរលំនឹង និង បម្រែបម្រួលថាមពលសេរីសម្រាប់ប្រតិកម្មនេះ

$E^0$ (ពិល) = $E^0 (Fe^{2+}/Fe) - E^0 (Co^{2+}/Co) = -0.44\ V - (-0.28\ V) = -0.16\ V$

តាមរូបមន្ត $E^o = \dfrac{0.0257\ V}{n} \ln K$ ដែល $n = 2$

យើងបាន $-0.16\ V = \dfrac{0.0257\ V}{2} \ln K$

នោះ $\ln K = -12.45$ ដោយ $\ln X = -12.45$ នាំឲ្យ $X = 4 \times 10^{-6}$

ដូចនេះយើងបាន $K = 4 \times 10^{-6}$

តាមរូបមន្ត $\Delta G^o = -nFE^o_{Cell} = -2 \times 96500\ J/V.mol \times (-0.16\ V) = 30.88\ kJ/mol$

៦. ក. គណនាតម្លៃថេរល្បឿននៃប្រតិកម្មនេះ

តាមរូបមន្ត $K = \dfrac{0.693}{t_{1/2}}$ ដែល $t_{1/2} = 8$ នាទី

ដូចនេះយើងបាន $K = \dfrac{0.693}{8\ min} = 0.0866\ min^{-1}$

ខ. គណនារយៈពេល (នាទី) ដើម្បីឲ្យស៊ុលផូរីលក្លរួសល់ 1 % នៃបរិមាណដើម

យើងមានសមាសធាតុស៊ុលផូរីលក្លរួដើម 100 % សមាសធាតុនេះបាននៅសល់ 1 % ដូចនេះផលធៀបភាគរយស្មើផលធៀបកំហាប់ $[A]_0 / [A]_t = 100\% / 1\% = 100$

តាមរូបមន្ត $\ln \dfrac{[A]_0}{[A]_t} = kt$

យើងបាន $\ln 100 = 0.0866\ min^{-1} \times t$

$2(\ln 2 + \ln 5) = 0.0866 \times t$ ដោយ $\ln 2 = 0.693, \ln 5 = 1.609$

$$t = \frac{2.302}{0.0433\ min^{-1}} = 53\ min$$

ដូចនេះយើងបាន $t = 53$ min

**វិធីទី១** តាមរូបមន្ត $\ln\frac{[A]_0}{[A]_t} = kt$ នាំឲ្យ $t = \frac{1}{k} \times \ln\frac{[A]_0}{[A]_t}$

យើងមានសមាសធាតុស៊ុលផួរីលក្លរដើម 100 % សមាសធាតុនេះបាននៅសល់ 1 % ដូចនេះផលធៀប

ភាគរយស្មើផលធៀបកំហាប់ $\frac{[A]_0}{[A]_t} = \frac{100}{1} = 100$

យើងបាន $t = \frac{1}{0.0866\ mn^{-1}} \times \ln 100$

$= \frac{1}{0.0866\ mn^{-1}} \times (2\ln 10) = 53$ នាទី

ដូចនេះរយៈពេលដែលត្រូវការ $t = 53$ min

**វិធីទី២** តាមរូបមន្ត $\ln\frac{[A]_t}{[A]_o} = -kt$ នាំឲ្យ $t = -\frac{1}{k} \times \ln\frac{[A]_t}{[A]_o}$

យើងមានសមាសធាតុស៊ុលផួរីលក្លរដើម 100 % សមាសធាតុនេះបាននៅសល់ 1% ដូចនេះ

ផលធៀបភាគរយស្មើផលធៀបកំហាប់ $\frac{[A]_t}{[A]_o} = \frac{1}{100} = 0.01$

យើងបាន $t = -\frac{1}{0.0866\ mn^{-1}} \times \ln 10^{-2}$

$= -\frac{1}{0.0866\ mn^{-1}} \times \ln 10^{-2} = 53$ នាទី

ដូចនេះរយៈពេលដែលត្រូវការ $t = 53$ min

៧. ក. គណនាម៉ាសអ៊ីយ៉ូដនៅសល់ក្នុងផាសទឹក

- **វិធីទី១:** តាង X ជាម៉ាសអ៊ីយ៉ូដក្នុងផាសទឹក

នោះ 2 mg – X ជាម៉ាសអ៊ីយ៉ូដក្នុងផាសសារធាតុរំលាយ $CCl_4$

ដោយ $\frac{\text{កំហាប់ } I_2 \text{ ក្នុងផាស } CCl_4}{\text{កំហាប់ } I_2 \text{ ក្នុងផាស } H_2O} = \frac{85}{1}$



ហួន គីមស្រ៊ា

$$\frac{\frac{2\ mg - X}{5\ mL}}{\frac{X}{25\ mL}} = 85 \quad \text{នាំឲ្យ} \quad \frac{2\ mg - X}{X} = 17$$




យើងបាន X = 0.11 mg

ដូចនេះកំហាប់អ៊ីយ៉ូដនៅសល់ក្នុងផាសទឹកគឺ 0.11 mg

ខ. គណនាម៉ាសអ៊ីយ៉ូដនៅសល់ក្នុងផាសទឹក

តាង X ជាម៉ាសអ៊ីយ៉ូដក្នុងផាសទឹកនោះ 0.11 mg – X

ជាម៉ាសអ៊ីយ៉ូដក្នុងផាសសារធាតុរំលាយ $CCl_4$

ដោយ $\frac{\text{កំហាប់ } I_2 \text{ ក្នុងផាស } CCl_4}{\text{កំហាប់ } I_2 \text{ ក្នុងផាស } H_2O} = \frac{85}{1}$

$$\frac{\frac{0.11\ mg - X}{5\ mL}}{\frac{X}{25\ mL}} = 85 \quad \text{នាំឲ្យ} \quad \frac{0.11\ mg - X}{X} = 17$$

យើងបាន $X = 6.11 \times 10^{-3}$ mg

ដូចនេះម៉ាសអ៊ីយ៉ូដនៅសល់ក្នុងផាសទឹកគឺ $6.11 \times 10^{-3}$ mg

- **វិធីទី២៖** ក. តាង X (mg) ជាម៉ាសអ៊ីយ៉ូដក្នុងផាសទឹក

  តាង Y (mg) ជាម៉ាសអ៊ីយ៉ូដក្នុងផាសផាសសារធាតុរំលាយ $CCl_4$

  យើងបាន X + Y = 2 mg

ដោយ $\frac{\text{កំហាប់ } I_2 \text{ ក្នុងផាស } CCl_4}{\text{កំហាប់ } I_2 \text{ ក្នុងផាស } H_2O} = \frac{85}{1}$

$$\frac{\frac{Y\ mg}{5\ mL}}{\frac{X\ mg}{25\ mL}} = 85 \quad \text{នាំឲ្យ } Y = 17X$$

យើងបាន 17 X + X = 2 mg នាំឲ្យ X = 0.11 mg

ដូចនេះកំហាប់អ៊ីយ៉ូដនៅសល់ក្នុងផាសទឹកគឺ 0.11 mg

ខ. គណនាម៉ាសអ៊ីយ៉ូដនៅសល់ក្នុងផាសទឹក

តាង X (mg) ជាម៉ាសអ៊ីយ៉ូដក្នុងផាសទឹក

តាង Y (mg) ជាម៉ាសអ៊ីយ៉ូដក្នុងផាសផាសសារធាតុរំលាយ $CCl_4$

យើងបាន $X + Y = 0.11$ mg

ដោយ $\frac{\text{កំហាប់ } I_2 \text{ ក្នុងផាស } CCl_4}{\text{កំហាប់ } I_2 \text{ ក្នុងផាស } H_2O} = \frac{85}{1}$

$\frac{\frac{Y\ mg}{5\ mL}}{\frac{X\ mg}{25\ mL}} = 85$ នាំឲ្យ $Y = 17X$

យើងបាន $17X + X = 0.11$ mg នាំឲ្យ $X = 6.11 \times 10^{-3}$ mg

ដូចនេះកំហាប់អ៊ីយ៉ូដនៅសល់ក្នុងផាសទឹកគឺ $6.11 \times 10^{-3}$ mg

- ចំណាំ: ចូរព្យាយាមដោះស្រាយវិធីផ្សេងទៀតតាមសមត្ថភាពដែលអាចធ្វើបាន
-

Prepared by **Houn Kimsrea**

November 29, 2017

**All rights reserved.**

No part of this compilation may be reproduced or distributed in any form or by any means, or stored in a database or retrieval system, without the prior written consent.

**រៀនមិនចេះមិនមែនមកពីយើងមិនឆ្លាតនោះទេ គ្រាន់តែគ្មានវិធីរៀនតែប៉ុណ្ណោះ ឬគ្រាន់តែបានសាកល្បង ១០ ០០០ វិធី ដែលមិនទាន់ប្រើការបាននៅឡើយ**

- <u>ចំនុចសំខាន់គួរចងចាំ</u>

## ស៊ីនេទិចគីមី

## CHEMICAL KINETICS

- **First Order Reaction:** $\ln\frac{[A]_t}{[A]_0} = -kt$ ឬ $\ln\frac{[A]_0}{[A]_t} = kt$; ប្រតិកម្មលំដាប់ ១

រយៈពេលពាក់កណ្ដាលប្រតិកម្ម គឺរយៈពេលដែលត្រូវការដើម្បីឲ្យកំហាប់អង្គធាតុប្រតិករថយចុះអស់ពាក់ កណ្ដាលនៃកំហាប់ដើម។ យើងបាន $[A]_t = \frac{[A]_0}{2}$ ឬ $[A]_0 = 2\,[A]_t$

ដោយ $\ln\frac{[A]_0}{[A]_t} = kt$ នាំឲ្យ $\ln\frac{2\,[A]_t}{[A]_t} = k\,t_{(1/2)}$

ដូចនេះ រយៈពេលពាក់កណ្ដាលប្រតិកម្ម **Half-life:** $t_{1/2} = \frac{\ln 2}{K} = \frac{0.693}{K}$ (**k: rate constant** ថេរល្បឿន)

- **Second Order Reaction:** $1/[A]_t = kt + 1 / [A]_0$; **Half-life:** $t_{1/2} = 1 / k[A]_0$ ប្រតិកម្មលំដាប់ ២

(**$[A]_0$ initial concentration of A** កំហាប់ដើម) (**$[A]_t$ final concentration of A** កំហាប់សល់)

## អេឡិចត្រូគីមី

## ELECTROCHEMISTRY

**The Standard Free Energy Change (1atm, 298 K)** បម្រែបម្រួលថាមពលសេរីស្តង់ដា

- $\Delta G^o = - RT \ln K = - nFE^o_{Cell}$

We obtain $E_{Cell^o} = \frac{RT}{nF}\ln K = \frac{8.314\frac{J}{mol.K}\times 298\,K}{n\times 96500\frac{J}{mol.K}} = \frac{0.0257\,V}{n}\ln K = \frac{0.0592\,V}{n}\log K$

- $E_{Cell^o} = \frac{0.0257\,V}{n}\ln K = \frac{0.0592\,V}{n}\log K$

ព្រោះ: $\ln X = 2.302 \log X$

$\Delta G = \Delta G^o + RT \ln Q$ Because $\Delta G = -nFE_{Cell}$ and $\Delta G^o = -nFE^o_{Cell}$

$-nFE_{Cell} = -nFE^o_{Cell} + RT \ln Q$

Dividing the equation through by – nF, we get

- សមីការ Nernst $E = E^o - \frac{0.0257\ V}{n} \ln Q$ ឬ $E = E^o - \frac{0.0592\ V}{n} \log Q$

R = 8.314 J/mol.K ថេរឧស្ម័ន

T = Temperature in K សីតុណ្ហភាព

n = moles of electron from balanced redox reaction ចំនួនម៉ូលអេឡិចត្រុងពេលសមីការមានលំនឹង

F = Faraday’s constant = 96500 J/V.mol ថេរហ្វារ៉ាដេ

K = Equilibrium constant (Q = K) ថេរលំនឹងប្រតិកម្ម

The relationships among $E_{Cell}^o$, K and $\Delta G^o$




All rights reserve

No part of this compilation may be reproduced or distributed in any form or by any means, or stored in a database or retrieval system, without the prior written consent.

| ΔG° | K | $E_{Cell}^{\circ}$ | Reaction Direction | Spontaneity |
|---|---|---|---|---|
| Negative (–) | > 1 | Positive (+) | Forward<br>ប្រតិកម្មតាមទិសស្រប | Spontaneous (Favors formation of products) |
| 0 | = 1 | 0 | No reaction<br>គ្មានប្រតិកម្ម | Reactants and products are equally favored |
| Positve (+) | < 1 | Negative (–) | Backward<br>ប្រតិកម្មតាមទិសច្រាស | Non-spontaneous (Favors formation of reactants) |

LEO says GER (Loss of Electron is Oxidation; Gain of Electron is Reduction)

*A New Ox*; Red CAP (Anode Negative Oxidation; Reduction CAthode Positive)

*A New CAP* (Anode Negative; CAthode Positive),

An Ox Red Cat (Anode Oxidation; Reduction Cathode)

*A*n *O*xygen atom *O*xidize become *N*egative and CA Reduces become Positive

(*A*node, *O*xidation, *N*egative) (CAthode, Reduction, Positive)

LEO says GER (Loss of Electron is Oxidation; Gain of Electron is Reduction)

*RIG* OIL (Reduction Is Gain of Electron; Oxidation Is Loss of Electron)

រៀបរៀង និងចងក្រងដោយ: ហួន គឹមស្រ៊ា

Tel: 098 472 472

ខ្ញុំមិនស្តាយក្រោយជាដាច់ខាត បើខ្ញុំធ្វើទៅបរាជ័យ ខ្ញុំដឹងថាបានរៀនអ្វីមួយ ប៉ុន្តែខ្ញុំពិតជាសោកស្តាយជាទីបំផុត បើខ្ញុំមិនបានសាកល្បងធ្វើវា

No part of this compilation may be reproduced or distributed in any form or by any means, or stored in a database or retrieval system, without the prior written consent.

- $K_D = \dfrac{\text{Concentration of solute in organic phase}}{\text{Concentration of solute in aqueous phase}} = \dfrac{m(org)/V(org)}{m(aq)/V(aq)}$

$= \dfrac{\text{កំហាប់អង្គធាតុរលាយក្នុងផាសសរីរាង្គ}}{\text{កំហាប់អង្គធាតុរលាយក្នុងផាសទឹក}}$

**$K_D$: Distribution ratio or Distribution coefficient or Partition coefficient:**

ផលធៀបរបាយ ឬ មេគុណបំបែក

## លំហាត់អនុវត្តន៍ស៊ីនេទិចគីមី

១. ប្រតិកម្មបំលែងពីស៊ីក្លូប្រូប៉ានទៅជាប្រូប៉ែននៅក្នុងផាសឧស្ម័ន គឺជាប្រតិកម្មលំដាប់ ១ ដែលមានតម្លៃថេរល្បឿន $6.5 \times 10^{-4} s^{-1}$ នៅសីតុណ្ហភាព $500\ ^0C$។

ក. ចូរសរសេរសមីការនៃប្រតិកម្មបំលែងពីស៊ីក្លូប្រូប៉ានទៅជាប្រូប៉ែន

ខ. គណនាកំហាប់ស៊ីក្លូប្រូប៉ានដែលនៅសល់ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តទៅអស់រយៈពេល 12 នាទី បើកំហាប់ដើមរបស់ស៊ីក្លូប្រូប៉ានស្មើនឹង 0.75 M។

គ. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីបំលែងស៊ីក្លូប្រូប៉ានឲ្យអស់ 75 %?

ឃ. គណនារយៈពេលពាក់កណ្ដាល (នាទី) ប្រតិកម្មនេះ

គេឲ្យ: $\ln 0.75 = -0.288$; $\ln 2 = 0.693$; $e^{-0.756} = 0.470$

ចម្លើយ:  ,**0.470 M, 35.5 min, 17.75 min**

២. ប្រតិកម្មបំបែកអេតានជាវ៉ាឌីកាល់មេទីលគឺជាប្រតិកម្មលំដាប់១ដែលមានថេរល្បឿនស្មើ $5.6 \times 10^{-4} s^{-1}$។

ក. ចូរសរសេរសមីការនៃប្រតិកម្មបំបែកអេតាន ទៅជារ៉ាឌីកាល់មេទីល

ខ. គណនាកំហាប់អេតាន ដែលនៅសល់ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តទៅអស់រយៈពេល 25 នាទី បើកំហាប់ដើមរបស់អេតាន ស្មើនឹង 0.88 M។

គ. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីបំលែងអេតានឲ្យសល់ 4%?

ឃ. គណនារយៈពេលកណ្ដាល (នាទី) ប្រតិកម្មនេះ

គេឲ្យ: ln 0.88 = –0.128; ln 2 = 0.693; ln 5 = 1.609; $e^{-0.968}$ = 0.380

ចម្លើយ: $C_2H_6 \rightarrow 2\ CH_3$; 0.38 M, 96 នាទី, 21 នាទី

៣. ប្រតិកម្មបំបែកអេទីលក្លរទៅជាអ៊ីដ្រូសែនក្លរ និង អេទីឡែននៅក្នុងផាសឧស្ម័ន គឺ ជាប្រតិកម្មលំដាប់ ១ ដែលមានថេរល្បឿន $7.5 \times 10^{-4}\ s^{-1}$ នៅសីតុណ្ហភាពខ្ពស់។

ក. ចូរសរសេរសមីការនៃប្រតិកម្មបំលែងពីអេទីលក្លរទៅជាអេទីឡែន

ខ. គណនាកំហាប់អេទីលក្លរដែលនៅសល់ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តទៅអស់រយៈពេល 15 នាទី បើកំហាប់ដើមរបស់អេទីលក្លរស្មើនឹង 0.40 M។

គ. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីបំលែងអេទីលក្លរឲ្យអស់ 95 %?

ឃ. គណនារយៈពេលកណ្ដាលប្រតិកម្មនេះ

(គេឲ្យ: ln 0.4 = – 0.916; ln 5 = 1.609; ln 2 = 0.693; $e^{-1.591}$ = 0.203)

ចម្លើយ: $C_2H_5Cl\ (g) \rightarrow C_2H_4\ (g) + HCl\ (g)$; 0.203 M, 66.5 នាទី, 15 នាទី

៤. ប្រតិកម្មបំបែកអ៊ីដ្រូសែនពែអុកស៊ីត ទៅជាឧស្ម័នអុកស៊ីសែន និង ទឹក គឺជាប្រតិកម្មលំដាប់ ១ ដែលមានតម្លៃថេរល្បឿនស្មើ $5.4 \times 10^{-5}\ s^{-1}$។

១. ចូរសរសេរសមីការនៃប្រតិកម្មបំបែកអ៊ីដ្រូសែនពែអុកស៊ីត ទៅជាឧស្ម័នអុកស៊ីសែន និង ទឹក

២. តើតម្លៃរយៈពេល (នាទី) ពាក់កណ្ដាលប្រតិកម្មបំបែកនេះស្មើប៉ុន្មាន?

៣. តើអ៊ីដ្រូសែនពែអុកស៊ីតបំបែកអស់ប៉ុន្មានភាគរយ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តអស់រយៈពេល 800 s។

៤. តើអ៊ីដ្រូសែនពែអុកស៊ីតបំបែកអស់ប៉ុន្មានភាគរយ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តអស់រយៈពេល 350 s។

៥. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីឲ្យអ៊ីដ្រូសែនពែអុកស៊ីតសល់ 10 %?

(គេឲ្យ: $e^{-0.0432}$ = 0.958; ln 2 = 0.693; ln 5 = 1.609; $e^{-0.0189}$ = 0.981)

ចម្លើយ: $2\ H_2O_2\ (aq) \rightarrow O_2\ (g) + 2\ H_2O\ (l)$; 214 នាទី; 4.2 %; 1.9 %; 710 នាទី

៦. ក. សមាសធាតុមួយបានបំបែកនៅសីតុណ្ហភាពជាក់លាក់មួយតាមប្រតិកម្មលំដាប់មួយ នៅរយៈពេល 6 ម៉ោង ក្រោយមក សមាសធាតុនោះបាននៅសល់ 20 %។ គណនាថេរល្បឿន រយៈពេលពាក់កណ្ដាល ប្រតិកម្ម និង រយៈពេលដែលត្រូវការដើម្បីបំបែកសមាសធាតុនេះឲ្យអស់ 20%។

ខ. សមាសធាតុ A មួយបានបំបែកនៅសីតុណ្ហភាពជាក់លាក់មួយ រយៈពេល 100 s ក្រោយមកសមាសធាតុនោះ បាននៅសល់ 50 %។ តើសមាសធាតុនេះនៅសល់ប៉ុន្មាន បន្ទាប់ពីប្រតិកម្មបំបែកអស់ រយៈពេល 200 s បើវាជា ប្រតិកម្មលំដាប់ ១?

គ. ប្រតិកម្មបំបែកស៊ុលផួរីលក្លរ ($SO_2Cl_2$) ទៅជាស្ពាន់ធ័រឌីអុកស៊ីត និង ឧស្ម័នក្លរ គឺជាប្រតិកម្មលំដាប់១ ដែលមានរយៈពេលពាក់កណ្ដាលប្រតិកម្មស្មើ 10 នាទី។

១. ចូរសរសេរសមីការនៃប្រតិកម្មបំបែកស៊ុលផួរីលក្លរ ទៅជាស្ពាន់ធ័រឌីអុកស៊ីត និង ឧស្ម័នក្លរ

២. គណនាតម្លៃថេរល្បឿននៃប្រតិកម្មនេះ

៣. គណនាកំហាប់ស៊ុលផួរីលក្លរ ដែលនៅសល់ បន្ទាប់ពីប្រតិកម្មប្រព្រឹត្តទៅអស់រយៈពេល 12 នាទី បើ កំហាប់ដើមរបស់ស៊ុលផួរីលក្លរស្មើនឹង 0.85 M។

៤. តើត្រូវការរយៈពេលប៉ុន្មាន (នាទី) ដើម្បីឲ្យស៊ុលផួរីលក្លរសល់ 5 %?

(គេឲ្យ: $\ln 0.85 = -0.163$; $\ln 2 = 0.693$; $\ln 20 = 2.995$; $e^{-0.9946} = 0.370$)

ចម្លើយ: $SO_2Cl_2 \rightarrow SO_2 + Cl_2$; 0.0693 /min; 0.370 M; 43 min

All rights reserve

Prepared by Houn Kimsrea

May 25, 2018

No part of this compilation may be reproduced or distributed in any form or by any means, or stored in a database or retrieval system, without the prior written consent.

**ប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី............**

វិញ្ញាសា
គីមីទី ៣៤

**រៀបរៀង ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៧**

**វិញ្ញាសា៖ ឯកទេសទី១ គីមីវិទ្យា រយៈពេល ៣ ម៉ោង**

ឈ្មោះ..................................លេខបន្ទប់...............លេខតុ.................ហត្ថលេខា.................

សម្រាប់និស្សិតគីមីត្រៀមប្រលង NIE Tel: 098 472 472

## ប្រធានវិញ្ញាសាគីមីវិទ្យាទី ៣៤

១. ចូរថ្លឹង និង បំពេញសមីការដូចខាងក្រោម:

ក. $CuS + HNO_3 \rightarrow Cu(NO_3)_2 + H_2SO_4 + NO + H_2O$

ខ. $As_2S_3 + ClO_3^- \rightarrow H_3AsO_4 + SO_4^{2-} + Cl^-$ (មជ្ឈដ្ឋានអាស៊ីត)

គ. $Ag + HS^- + CrO_4^{2-} \rightarrow Ag_2S + Cr(OH)_3$ (មជ្ឈដ្ឋានបាស)

ឃ. $^{214}_{84}Po + \alpha + \quad \rightarrow {}^{222}_{86}Rn$

ង. $^{238}_{92}U \rightarrow \quad + He$

២. កាចុង $M^{2+}$ (ជាប្រភេទអាតូមមួយ) មានរបាយអេឡិចត្រុងនៅស្រទាប់ក្រៅបង្អស់ $3p^6$។

ក. សរសេររបាយអេឡិចត្រុងតាមទម្រង់ស្រទាប់រង s p និង ការបំពេញអេឡិចត្រុងរបស់វាទៅអ័រប៊ីតាល់នីមួយៗ។ តើ $M^{2+}$ មានចំនួនអេឡិចត្រុងសរុបប៉ុន្មានក្នុងអ័រប៊ីតាល់ p ទាំងអស់ប៉ុន្មាន?

ខ. តើ M ស្ថិតក្នុងខួបទីប៉ុន្មាន ក្រុមណា និង មានឈ្មោះអ្វី?

គ. តើអ៊ីយ៉ុង $M^{2+}$ ជាប្រភេទប៉ារ៉ាម៉ាញ៉េទិច ឬ ដ្យាម៉ាញ៉េទិច? ហេតុអ្វី?

៣. តើគេត្រូវការចាំបាច់កាំរស្មីដែលមានជំហានរលកអតិបរមាប៉ុន្មាន ដែលអាចមានថាមពលគ្រប់គ្រាន់ដើម្បី ផ្តាច់ថាមពលសម្ព័ន្ធអុកស៊ីសែន 496 KJ / mol? តើកាំរស្មីដែលត្រូវនឹងជំហានរលកនោះមានឈ្មោះអ្វី?

គេឲ្យ: $h = 6.626 \times 10^{-34}$ J.s; $c = 3 \times 10^8$ m/s, $N_A = 6.022 \times 10^{23}$ atoms/mol

៤. ពិលវ៉ុលតាអ៊ិច ឬ ពិលហ្គាវ៉ានិចត្រូវបានបង្កើតដោយប្រើកន្លះពិលពីរ។ កន្លះពិលទីមួយផ្សំឡើងដោយអ៊ីដ្រូ

សែនស្តង់ដាដែលមានអេឡិចត្រូតលោហៈប្លាទីន និង កន្លះពិលទីពីរផ្សំឡើងដោយលោហៈប្រាក់ និង ប្រាក់ក្លរ។ គំនូសបំព្រួញពិលហ្គាវ៉ានិចគឺៈ Pt | $H_2$ (1 atm) | $H_3O^+$ (1 M) ‖ $Cl^-$ (1.00 x $10^{-3}$ M, $Ag^+$ (? M) | AgCl | Ag

កម្លាំងអគ្គីសនីចលកនៃថ្មពិលនេះមានតម្លៃ 0.397 V។ ចូរគណនាកំហាប់ជាម៉ូល $Ag^+$ និង ផលគុណកម្រិតរលាយ AgCl នៅសីតុណ្ហភាព 25 °C។ គេឲ្យៈ $E^o(Ag^+ / Ag) = 0.80$ V, ln X = -15.6 → X = 1.6 x $10^{-7}$

៥. សូលុយស្យុងទឹកអ៊ីយ៉ូដមួយមានមាឌ 0.100 L មានកំហាប់អ៊ីយ៉ូតរលាយក្នុងនោះ 2 x $10^{-3}$ M។ គេបន្ថែម 0.025 L នៃសារធាតុរំលាយ $CCl_4$ ចូលដើម្បីដំណើរការញែកយកធាតុអ៊ីយ៉ូដចេញពីសូលុយស្យុងទឹកនោះ។ គេដឹងថានៅសីតុណ្ហភាព 25 °C អ៊ីយ៉ូដអាចរលាយចូលអង្គធាតុរំលាយ $CCl_4$ បាន 85 ដងច្រើនជាងរលាយចូលក្នុងទឹកនៅលក្ខខណ្ឌពិសោធតាមលំនឹងគីមី

$$I_2\ (aq) \rightleftharpoons I_2\ (CCl_4)$$

ក. បន្ទាប់ពីការញែក តើមានអ៊ីយ៉ូដនៅសល់ក្នុងផាសទឹកប៉ុន្មាន?

ខ. បើគេញែកវាជាលើកទីពីរដោយប្រើ $CCl_4$ 0.025 L ថ្មីទៀតតើមានអ៊ីយ៉ូដប៉ុន្មាននឹងនៅសល់ក្នុងផាសទឹក?

៦. មេដាយមួយជាសំលោហៈផ្សំឡើងពីលោហៈប្រាក់ និងទង់ដែង។ គេរំលាយ 1.12 g នៃមេដាយទៅក្នុង 19.6 g នៃសូលុយស្យុង $H_2SO_4$ ខាប់ក្តៅ។ ក្រោយប្រតិកម្មចប់គេទទួលបានឧស្ម័នស៊ុលផួរី និង សូលុយស្យុង B។ គេបន្ថែមសូលុយស្យុង $Ba(NO_3)_2$ ទៅក្នុងសូលុយស្យុងដែលទទួលបានក្រោយពីអុកស៊ីតកម្មឧស្ម័នស៊ុលផួរីដោយទឹកប្រូមលើសចប់ប្រតិកម្មគេទទួលបានកករ 1.864 g។

ក. គណនាម៉ាសប្រាក់ និងម៉ាសទង់ដែងដែលមាននៅក្នុងល្បាយដើម

ខ. គណនាកំហាប់ភាគរយសូលុយស្យុង $H_2SO_4$ ខាប់ខាងលើបើគេដឹងថា $H_2SO_4$ សុទ្ធ 10 % ចូលរួមប្រតិកម្មជាមួយប្រាក់ និង ទង់ដែង

គ. បើគេយក ½ នៃសូលុយស្យុង $H_2SO_4$ ខាងលើទៅពង្រាវ នោះគេទទួលបានតម្លៃ pH = 2។ តើមាឌរបស់សូលុយស្យុងនេះស្មើប៉ុន្មាន? គេឲ្យៈ Ag = 108, Cu = 64, S = 32, Ba = 137

៧. ថ្មមួយដុំមានផ្ទុក $^{238}_{92}U$ និង $^{206}_{82}Pb$ ត្រូវបានគេត្រួតពិនិត្យអាយុកាលរបស់វា។ $^{206}_{82}Pb$ គឺជាផលិតផលនៃការបំបែករបស់ $^{238}_{92}U$។ ពាក់កណ្តាលជីវិតនៃអាតូម $^{238}_{92}U$ បំបែកជា $^{206}_{82}Pb$ មានតម្លៃស្មើ 4.5 x $10^9$ ឆ្នាំ។

ក. ចូរសរសេរសមីការបំបែកអាតូម $^{238}_{92}U$ ជាអាតូម $^{206}_{82}Pb$ បើអាតូម $^{238}_{92}U$ បញ្ចេញភាគល្អិត α និងអេឡិចត្រុង

ខ. ចូរគណនាផលធៀប $^{206}_{82}Pb$ និង $^{238}_{92}U$ ក្នុងដុំថ្មនេះ បើវាមានអាយុកាល 7.6 x $10^8$ ឆ្នាំ។

គេឲ្យៈ ln 2 = 0.693, ln X = - 0.117 → X = 0.889

ចម្លើយប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញា+១) ជំនាន់ទី............

វិញ្ញាសា គីមីទី ៣៤

រៀបរៀង ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៧

វិញ្ញាសា៖ ឯកទេសទី១ គីមីវិទ្យា រយៈពេល ៣ ម៉ោង

ឈ្មោះ..................................លេខបន្ទប់...............លេខតុ.................ហត្ថលេខា.................

(សម្រាប់និស្សិតគីមីត្រៀមប្រលង NIE) Tel: 098 472 472

## ដំណោះស្រាយប្រធានវិញ្ញាសាគីមីវិទ្យាទី៣៤

១. ចូរថ្លឹង និង បំពេញសមីការដូចខាងក្រោម:

ក. $CuS + HNO_3 \rightarrow Cu(NO_3)_2 + H_2SO_4 + NO + H_2O$

ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+2\ -2}{CuS} + \overset{+1\ +5\ -2}{HNO_3} \longrightarrow \overset{+2\ +5\ -2}{Cu(NO_3)_2} + \overset{+1\ +6\ -2}{H_2SO_4} + \overset{+2\ -2}{NO} + H_2O$$

យើងកំណត់យកចំនួនអុកស៊ីតកម្ម S = -2 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol CuS ស្មើ 8 និង

កំណត់យកចំនួនអុកស៊ីតកម្ម N = +5 ដូចនេះចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $HNO_3$ ស្មើ 3

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$3\,CuS + 14\,HNO_3 \rightarrow 3\,Cu(NO_3)_2 + 3\,H_2SO_4 + 8\,NO + 4\,H_2O$$

ថ្លឹងសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

$$CuS + 4\,H_2O \rightarrow Cu^{2+} + SO_4^{2-} + 8\,H^+ + 8\,e^-$$

$$NO_3^- + 4\,H^+ + 3\,e^- \rightarrow NO + 2\,H_2O$$

ដូចនេះសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

$$3\,CuS + 8\,NO_3^- + 8\,H^+ \rightarrow 3\,Cu^{2+} + 3\,SO_4^{2-} + 8\,NO + 4\,H_2O$$

អង្គខាងឆ្វេងថែម 6 $H^+$ និង 6 $NO_3^-$

អង្គខាងស្តាំក៏ថែម 6 $H^+$ និង 6 $NO_3^-$

ដូចនេះយើងបានសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

$$3\,CuS + 14\,HNO_3 \rightarrow 3\,Cu(NO_3)_2 + 3\,H_2SO_4 + 8\,NO + 4\,H_2O$$

ខ. $As_2S_3 + ClO_3^- \rightarrow H_3AsO_4 + SO_4^{2-} + Cl^-$ (មជ្ឈដ្ឋានអាស៊ីត)

ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{+3\ -2}{As_2S_3} + \overset{+5\ -2}{ClO_3^-} \longrightarrow \overset{+1\ +5\ -2}{H_3AsO_4} + \overset{+6\ -2}{SO_4^{2-}} + \overset{-1}{Cl^-}$$

យើងកំណត់យកចំនួនអុកស៊ីតកម្ម As = +3, S = -2 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol $As_2S_3$ ស្មើ 28 និងកំណត់យកចំនួនអុកស៊ីតកម្ម Cl = +5 ដូចនេះចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $ClO_3^-$ ស្មើ 6

ដូចនេះសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$6\,As_2S_3 + 28\,ClO_3^- + 36\,H_2O \rightarrow 12\,H_3AsO_4 + 18\,SO_4^{2-} + 28\,Cl^- + 36\,H^+$$

$$3\,As_2S_3 + 14\,ClO_3^- + 18\,H_2O \rightarrow 6\,H_3AsO_4 + 9\,SO_4^{2-} + 14\,Cl^- + 18\,H^+$$

ថ្លឹងសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

$$As_2S_3 + 20\,H_2O \rightarrow 2\,H_3AsO_4 + 3\,SO_4^{2-} + 34\,H^+ + 28\,e^-$$

$$ClO_3^- + 6\,H^+ + 6\,e^- \rightarrow Cl^- + 3\,H_2O$$

ដូចនេះយើងបានសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

$$6\,As_2S_3 + 28\,ClO_3^- + 36\,H_2O \rightarrow 12\,H_3AsO_4 + 18\,SO_4^{2-} + 28\,Cl^- + 36\,H^+$$

$$3\,As_2S_3 + 14\,ClO_3^- + 18\,H_2O \rightarrow 6\,H_3AsO_4 + 9\,SO_4^{2-} + 14\,Cl^- + 18\,H^+$$

គ. $Ag + HS^- + CrO_4^{2-} \rightarrow Ag_2S + Cr(OH)_3$ (មជ្ឈដ្ឋានបាស)

ថ្លឹងសមីការតុល្យការតាមវិធីបម្រែបម្រួលចំនួនអុកស៊ីតកម្ម

$$\overset{0}{Ag} + \overset{+1\ -2}{HS^-} + \overset{+6\ -2}{CrO_4^{2-}} \longrightarrow \overset{+1\ -2}{Ag_2S} + \overset{+3\ -2\ +1}{Cr(OH)_3}$$

យើងកំណត់យកចំនួនអុកស៊ីតកម្ម Ag = 0 ដូចនេះចំនួនអុកស៊ីតកម្មកើនសរុបក្នុង 1 mol Ag ស្មើ 2 និង កំណត់យកចំនួនអុកស៊ីតកម្ម Cr = +6 ដូចនេះចំនួនអុកស៊ីតកម្មថយចុះសរុបក្នុង 1 mol $CrO_4^{2-}$ ស្មើ 3

$$6\,Ag + 3\,HS^- + 2\,CrO_4^{2-} + 5\,H_2O \rightarrow 3\,Ag_2S + 2\,Cr(OH)_3 + 7\,OH^-$$

ថ្លឹងសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

$$2\,Ag + HS^- + OH^- \rightarrow Ag_2S + H_2O + 2e^-$$

$$CrO_4^{2-} + 4\,H_2O + 3\,e^- \rightarrow Cr(OH)_3 + 5\,OH^-$$

ដូចនេះយើងបានសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

$$6\,Ag + 3\,HS^- + 2\,CrO_4^{2-} + 5\,H_2O \rightarrow 3\,Ag_2S + 2\,Cr(OH)_3 + 7\,OH^-$$

**វិធីកំណត់លេខមេគុណ $OH^-$ (Method for Assigning hydroxide ion coefficients)**

១. កំណត់ចំនួនអុកស៊ីតកម្មអាតូម (ចំពោះអាតូមដែលមានចំនួនអុកស៊ីតកម្មប្រែប្រួលតែប៉ុណ្ណោះ)

២. កំណត់បម្រែបម្រួលចំនួនអុកស៊ីតកម្មរបស់អាតូម (n.o ថយវាចាប់យកអេឡិចត្រុង n.o កើនវាបោះបង់អេឡិចត្រុង)

៣. គណនាបន្ទុកសរុបនៅអង្គដែលគ្មាន $OH^-$ រួចថែមលេខមេគុណ $OH^-$ ដើម្បីឲ្យបន្ទុកស្មើគ្នា

(Kimsrea's First Method) (20/01/2020)

Step1 $CrO_4^{2-} + H_2O \rightarrow Cr(OH)_3 + OH^-$

n.o(Cr)=+6 n.o(Cr)=+3

Step2 $\Delta n.o(Cr) = +3 - (+6) = -3$

ចំនួនអុកស៊ីតកម្មថយចុះ ដោយ Cr ១ ថយចុះ –3 ដូចនេះ Cr វានឹងចាប់យក ៣អេឡិចត្រុង

Step3    $CrO_4^{2-} + H_2O + 3e^- \rightarrow Cr(OH)_3 + OH^-$

ដោយ Cr ១ ថយចុះ –3 នោះយើងត្រូវថែម៣អេឡិចត្រុងខាងឆ្វេង (វាចាប់យកអេឡិចត្រុង)

ដូចនេះយើងបាន    $CrO_4^{2-} + H_2O + 3e^- \rightarrow Cr(OH)_3 + OH^-$

ថ្លឹងបន្ទុកៈ ខាងឆ្វង   (–2)+( –3) = –5        ខាងស្តាំ 5(–1) = –5

ដូចនេះយើងត្រូវថែម 5 $OH^-$ ខាងឆ្វេងដើម្បីឲ្យបន្ទុកស្មើគ្នា

ដូចនេះសមីការតុល្យការតាមវិធីពាក់កណ្តាលប្រតិកម្ម

$$CrO_4^{2-} + 4\,H_2O + 3\,e^- \rightarrow Cr(OH)_3 + 5\,OH^-$$

**វិធីកំណត់លេខមេគុណ $OH^-$ (Method for Assigning hydroxide ion coefficients)**

**(Kimsrea's Second Method) (20/01/2020)**

១. សរសេរកន្លះសមីការដែលមិនមានលំនឹងដោយបន្ថែមអ៊ីដ្រុកស៊ីត ($OH^-$) អង្គខ្វះអាតូមអុកស៊ីសែន (O)

ដោយបន្ថែម $H_2O$ នៅអង្គណាខ្វះអាតូមអ៊ីដ្រូសែន (H)

$$MnO_4^- + H_2O \rightarrow MnO_2 + OH^-$$

២. តាងអថេរ æ ជាមេគុណ $OH^-$ (æ$OH^-$) និង $\frac{æ}{2}$ ជាមេគុណ $H_2O$ ($\frac{æ}{2}$ $H_2O$)

$$MnO_4^- + \frac{æ}{2}H_2O \rightarrow MnO_2 + æ\,OH^-$$

ករណីគ្មានអាតូមអ៊ីដ្រូសែន
អង្គដែលមានអ៊ីដ្រុកស៊ីត

៣. ថ្លឹងចំនួនអាតូមអុកស៊ីសែនដើម្បីរកតម្លៃអថេរ æ

$$MnO_4^- + \frac{æ}{2}H_2O \rightarrow MnO_2 + æ\,OH^-$$

$4 + \frac{æ}{2} = 2 + æ$ យើងបាន æ = 4

$$MnO_4^- + 2\,H_2O \rightarrow MnO_2 + 4\,OH^-$$

ថ្លឹងបន្ទុកៈ ខាងឆ្វង (–1) +(–3) = –4        ខាងស្តាំ –4

ដូចនេះយើងត្រូវថែម $3e^-$ ខាងអង្គដែលមានបន្ទុកធំដើម្បីឲ្យបន្ទុកស្មើគ្នា។

$$MnO_4^- + 2\,H_2O + 3e^- \rightarrow MnO_2 + 4\,OH^-$$

ឃ. $^{214}_{84}Po + 2\,^{4}_{2}\alpha + 2\,^{0}_{-1}e \rightarrow {}^{222}_{86}Rn$

ចំនួនម៉ាស (A) សរុបអង្គខាងឆ្វេងដៃ និងខាងស្តាំ: 214 + 2(4) + 0 = 222

លេខអាតូមិច (Z) សរុបអង្គខាងឆ្វេងដៃ និងខាងស្តាំ: 84 + 4 +(–2) = 86

ង. $^{238}_{92}U \rightarrow {}^{234}_{90}Th + {}^{4}_{2}He$

២. ក. សរសេររបាយអេឡិចត្រុងតាមទម្រង់ស្រទាប់រង s p គឺ $1s^2\ 2s^2\ 2p^6\ 3s^2\ 3p^6$។

$M^{2+}$ មានចំនួនអេឡិចត្រុងសរុបក្នុងអ័រប៊ីតាល់ p គឺ 12។

ខ. សរសេររបាយអេឡិចត្រុង M តាមទម្រង់ស្រទាប់រង s p គឺ $1s^2\ 2s^2\ 2p^6\ 3s^2\ 3p^6\ 4s^2$

M ស្ថិតក្នុងខួបទី 4 ក្រុមទី II និងមានឈ្មោះកាល់ស្យូម។

គ. អ៊ីយ៉ុង $M^{2+}$ ជាប្រភេទដ្យាម៉ាញ៉េទិច ព្រោះគ្មានអេឡិចត្រុងសេរីក្នុងស្រទាប់នីមួយៗទេ។

៣. គណនាថាមពលគ្រប់គ្រាន់ដើម្បីផ្តាច់ថាមពលសម្ព័ន្ធអុកស៊ីសែនមួយម៉ូលេគុល

យើងបាន: $\frac{496\ KJ}{1\ mol} \times \frac{1\ mol}{6.022 \times 10^{23}\ \text{ម៉ូលេគុល}} = 8.24 \times 10^{-19}$ J / ម៉ូលេគុល

តាមរូបមន្ត: $\lambda = \frac{hc}{E} = \frac{(6.626 \times 10^{-34}\ J.s)(3 \times 10^{8}\ m/s)}{8.24 \times 10^{-19}\ J} = 2.41 \times 10^{-7}\ m = 241\ nm$

ដូចនេះ គេត្រូវការចាំបាច់កាំរស្មីដែលមានជំហានរលកអតិបរមាស្មើ 241 nm។ កាំរស្មីដែលត្រូវនឹងជំហានរលកនោះមានឈ្មោះ កាំរស្មីស្វាយអ៊ុលត្រា។

**Wavelength formula: $C = \lambda V$**

**Where, C: speed of light ($3 \times 10^8$ m/s), λ: Wavelength (m), V: frequency (Hz or $s^{-1}$)**

**Plank's equation: $E = hV = h\frac{C}{\lambda}$, which, $h = 6.626 \times 10^{-34}$ J.s**

៤. **វិធីទី១៖** សមីការពាក់កណ្ដាលពិលនីមួយៗ

$H_2 (g) + 2 H_2O (l) \rightarrow 2 H_3O^+ (aq) + 2e^-$ (អាណូត)

$2 Ag^+ (aq) + 2e^- \rightarrow 2 Ag (s)$ (កាតូត)

យើងបានសមីការតុល្យការ: $2 Ag^+ (aq) + H_2 (g) + 2 H_2O (l) \rightarrow 2 H_3O^+ (aq) + 2 Ag (s)$

$\Delta E^0 = E^0$ (កាតូត) $- E^0$ (អាណូត) $= 0.80 - 0.00 = 0.80$ V

$$Q = \frac{[H_3O^+]^2}{[Ag^+]^2 \times P(H_2)} = \frac{1}{[Ag^+]^2}$$ ដែល $P(H_2) = 1$ atm និង $[H_3O^+] = 1$ M

តាមសមីការ $E = E^0 - \frac{0.0257\ V}{n} \ln Q$ ដែល $E = 0.397$ V និង $n = 2$

យើងបាន $0.397\ V = 0.80\ V - \frac{0.0257\ V}{2} \ln \frac{1}{[Ag^+]^2}$

នោះ $\ln [Ag^+] = -15.6$ ដោយ $\ln X = -15.6$ នាំឲ្យ $X = 1.6 \times 10^{-7}$

ដូចនេះយើងបាន $[Ag^+] = 1.6 \times 10^{-7}$ M

តាមផលគុណកម្រិតរលាយនៃ AgCl

$K_{sp} = [Ag^+][Cl^-] = 1.6 \times 10^{-7} \times 1.00 \times 10^{-3} = 1.6 \times 10^{-10}$

ដូចនេះផលគុណកម្រិតរលាយ AgCl នៅសីតុណ្ហភាព 25 °C គឺ $1.6 \times 10^{-10}$

**វិធីទី២៖** សមីការពាក់កណ្ដាលពិលនីមួយៗលំនាំរេដុកម្មនៃគូ $H_3O^+ / H_2$

$2 H_3O^+ (aq) + 2e^- \rightarrow H_2 (g) + 2 H_2O (l)$ $E^0 = 0.00$ V

តាមសមីការ $E = E^0 - \frac{0.0257\ V}{n} \ln K$ ដែល $E^\circ = 0.00$ V និង $n = 2$

ដោយ $K = \frac{P(H_2)}{[H_3O^+]^2} = 1$ ដែល $P(H_2) = 1$ atm និង $[H_3O^+] = 1$ M

យើងបាន $E = 0.00\ V - \frac{0.0257\ V}{2} \ln 1 = 0.00$ V

សមីការពាក់កណ្ដាលពិលនីមួយៗលំនាំរេដុកម្មនៃគូ $Ag^+ / Ag$

$$Ag^+ (aq) + 1 e^- \rightarrow Ag (s) \qquad E^\circ = 0.80 \text{ V}$$

តាមសមីការ $E = E^0 - \frac{0.0257 \text{ V}}{n} \ln K$ ដែល $E^\circ = 0.80$ V និង $n = 1$

យើងបាន $E = 0.80 \text{ V} - \frac{0.0257 \text{ V}}{1} \ln \frac{1}{[Ag^+]}$ ដោយ $K = \frac{1}{[Ag^+]}$

ដោយសមីការតុល្យការ: $2 Ag^+ (aq) + H_2 (g) + 2 H_2O (l) \rightarrow 2 H_3O^+ (aq) + 2 Ag (s)$

យើងបាន $\Delta E = E (Ag^+ / Ag) - E (H_3O^+ / H_2)$

$$0.397 \text{ V} = 0.80 \text{ V} - \frac{0.0257 \text{ V}}{1} \ln \frac{1}{[Ag^+]} - 0.00 \text{ V}$$

$$0.397 \text{ V} = 0.80 \text{ V} + 0.0257 \text{ V} \ln [Ag^+]$$

នោះ $\ln [Ag^+] = -15.6$ ដោយ $\ln X = -15.6$ នាំឲ្យ $X = 1.6 \times 10^{-7}$

ដូចនេះយើងបាន $[Ag^+] = 1.6 \times 10^{-7}$ M

តាមផលគុណកម្រិតរលាយនៃ AgCl

$$K_{sp} = [Ag^+][Cl^-] = 1.6 \times 10^{-7} \times 1.00 \times 10^{-3} = 1.6 \times 10^{-10}$$

ដូចនេះផលគុណកម្រិតរលាយ AgCl នៅសីតុណ្ហភាព 25 °C គឺ $1.6 \times 10^{-10}$

**វិធីទី៣៖** សមីការពាក់កណ្ដាលពិលនីមួយៗ

$H_2 (g) + 2 H_2O (l) \rightarrow 2 H_3O^+ (aq) + 2e^-$ (អាណូត)

$2 Ag^+ (aq) + 2e^- \rightarrow 2 Ag (s)$ (កាតូត)

យើងបានសមីការតុល្យការ: $2 Ag^+ (aq) + H_2 (g) + 2 H_2O (l) \rightarrow 2 H_3O^+ (aq) + 2 Ag (s)$

$\Delta E^0 = E^0$ (កាតូត) $- E^0$ (អាណូត) $= 0.80 - 0.00 = 0.80$ V

$$Q = \frac{[H_3O^+]^2}{[Ag^+]^2 \times P(H_2)} = \frac{1}{[Ag^+]^2}$$ ដែល $P (H_2) = 1$ atm និង $[H_3O^+] = 1$ M

តាមសមីការ $E = E^0 - \frac{0.0592\ V}{n}\log Q$ ដែល $E = 0.397\ V$ និង $n = 2$

យើងបាន $0.397\ V = 0.80\ V - \frac{0.0592\ V}{2}\log\frac{1}{[Ag^+]^2}$

នោះ $\log[Ag^+] = -6.81$ ដោយ $\log X = -6.81$ នាំឲ្យ $X = 1.6 \times 10^{-7}$

ដូចនេះយើងបាន $[Ag^+] = 1.6 \times 10^{-7}\ M$

តាមផលគុណកម្រិតរលាយនៃ AgCl

$K_{sp} = [Ag^+][Cl^-] = 1.6 \times 10^{-7} \times 1.00 \times 10^{-3} = 1.6 \times 10^{-10}$

ដូចនេះផលគុណកម្រិតរលាយ AgCl នៅសីតុណ្ហភាព 25 °C គឺ $1.6 \times 10^{-10}$

**វិធីទី៤៖** សមីការពាក់កណ្ដាលពិលនីមួយៗលំនាំរេដុកម្មនៃគូ $H_3O^+ / H_2$

$$2\ H_3O^+\ (aq) + 2e^- \rightarrow H_2\ (g) + 2\ H_2O\ (l) \qquad E^0 = 0.00\ V$$

តាមសមីការ $E = E^0 - \frac{0.0592\ V}{n}\log K$ ដែល $E^\circ = 0.00\ V$ និង $n = 2$

ដោយ $K = \frac{P(H_2)}{[H_3O^+]^2} = 1$ ដែល $P(H_2) = 1\ atm$ និង $[H_3O^+] = 1\ M$

យើងបាន $E = 0.00\ V - \frac{0.0592\ V}{2}\log 1 = 0.00\ V$

សមីការពាក់កណ្ដាលពិលនីមួយៗលំនាំរេដុកម្មនៃគូ $Ag^+ / Ag$

$$Ag^+\ (aq) + 1\ e^- \rightarrow Ag\ (s) \qquad E^\circ = 0.80\ V$$

តាមសមីការ $E = E^0 - \frac{0.0592\ V}{n}\log K$ ដែល $E^\circ = 0.80\ V$ និង $n = 1$

យើងបាន $E = 0.80\ V - \frac{0.0592\ V}{1}\log\frac{1}{[Ag^+]}$ ដោយ $K = \frac{1}{[Ag^+]}$

ដោយសមីការតុល្យការ: $2\ Ag^+\ (aq) + H_2\ (g) + 2\ H_2O\ (l) \rightarrow 2\ H_3O^+\ (aq) + 2\ Ag\ (s)$

យើងបាន $\Delta E = E\ (Ag^+ / Ag) - E\ (H_3O^+ / H_2)$

$$0.397\text{ V} = 0.80\text{ V} - \frac{0.0592\text{ V}}{1}\log\frac{1}{[Ag^+]} - 0.00\text{ V}$$

$$0.397\text{ V} = 0.80\text{ V} + 0.0592\text{ V}\log[Ag^+]$$

នោះ $\log[Ag^+] = -6.81$ ដោយ $\log X = -6.81$ នាំឲ្យ $X = 1.6 \times 10^{-7}$

ដូចនេះយើងបាន $[Ag^+] = 1.6 \times 10^{-7}$ M

តាមផលគុណកម្រិតរលាយនៃ AgCl

$K_{sp} = [Ag^+][Cl^-] = 1.6 \times 10^{-7} \times 1.00 \times 10^{-3} = 1.6 \times 10^{-10}$

ដូចនេះផលគុណកម្រិតរលាយ AgCl នៅសីតុណ្ហភាព 25 °C គឺ $1.6 \times 10^{-10}$

៥. ក. វិធីទី១៖ តាង X ជាកំហាប់អ៊ីយ៉ូដក្នុងផាសទឹក

នោះ $2 \times 10^{-3}$ M – X ជាកំហាប់អ៊ីយ៉ូដក្នុងផាសសារធាតុរំលាយ $CCl_4$

ដោយ $\frac{\text{កំហាប់ } I_2 \text{ ក្នុងផាស } CCl_4}{\text{កំហាប់ } I_2 \text{ ក្នុងផាស } H_2O} = \frac{85}{1}$

$$\frac{\frac{2 \times 10^{-3} - X}{0.025}}{\frac{X}{0.1}} = 85 \quad \text{នាំឲ្យ} \quad \frac{2 \times 10^{-3} - X}{X} = 21.25$$

យើងបាន $X = 8.98 \times 10^{-5}$ M

ដូចនេះកំហាប់អ៊ីយ៉ូដនៅសល់ក្នុងផាសទឹកគឺ $8.98 \times 10^{-5}$ M

ខ. វិធីទី១៖ តាង X ជាកំហាប់អ៊ីយ៉ូដក្នុងផាសទឹក

នោះ $8.98 \times 10^{-5}$ M – X ជាកំហាប់អ៊ីយ៉ូដក្នុងផាសសារធាតុរំលាយ $CCl_4$

$$\frac{\frac{8.98 \times 10^{-5} - X}{0.025}}{\frac{X}{0.1}} = 85 \quad \text{នាំឲ្យ} \quad \frac{8.98 \times 10^{-5} - X}{X} = 21.25$$

យើងបាន $X = 4.04 \times 10^{-6}$ M

ដូចនេះកំហាប់អ៊ីយ៉ូដនៅសល់ក្នុងផាសទឹកគឺ $4.04 \times 10^{-6}$ M

- **ក. វិធីទី២៖** តាង X (mol/L) ជាកំហាប់អ៊ីយ៉ូដក្នុងផាសទឹក

តាង Y (mol/L) ជាកំហាប់អ៊ីយ៉ូដក្នុងផាសសារធាតុរំលាយ $CCl_4$

យើងបាន $X + Y = 2 \times 10^{-3}$ M

ដោយ $\frac{\text{កំហាប់ } I_2 \text{ ក្នុងផាស } CCl_4}{\text{កំហាប់ } I_2 \text{ ក្នុងផាស } H_2O} = \frac{85}{1}$

$$\frac{\frac{Y}{0.025}}{\frac{X}{0.1}} = 85$$ នាំឲ្យ $Y = 21.25X$

យើងបាន $21.25X + X = 2 \times 10^{-3}$ M នាំឲ្យ $X = 8.98 \times 10^{-5}$ M

ដូចនេះកំហាប់អ៊ីយ៉ូដនៅសល់ក្នុងផាសទឹកគឺ $8.98 \times 10^{-5}$ M

**ក. វិធីទី៣៖** តាង X ជាកំហាប់អ៊ីយ៉ូដក្នុងផាសសរីរាង្គធាតុរំលាយ $CCl_4$

នោះ $2 \times 10^{-3}$ M – X ជាកំហាប់អ៊ីយ៉ូដក្នុងផាសទឹក

ដោយ $\frac{\text{កំហាប់ } I_2 \text{ ក្នុងផាស } CCl_4}{\text{កំហាប់ } I_2 \text{ ក្នុងផាស } H_2O} = \frac{85}{1}$

$$\frac{\frac{X}{0.025}}{\frac{2 \times 10^{-3} - X}{0.1}} = 85$$ នាំឲ្យ $\frac{X}{2 \times 10^{-3} - X} = 21.25$

យើងបានកំហាប់អ៊ីយ៉ូដក្នុងផាសសរីរាង្គ $X = 1.91 \times 10^{-3}$ M

ដូចនេះកំហាប់អ៊ីយ៉ូដនៅសល់ក្នុងផាសទឹកគឺ $2 \times 10^{-3}$ M – $1.91 \times 10^{-3}$ M = $9 \times 10^{-5}$ M

**ខ. វិធីទី២៖** គណនាកំហាប់អ៊ីយ៉ូដសល់ក្នុងផាសទឹក

- ខ តាង X (mol/L) ជាកំហាប់អ៊ីយ៉ូដក្នុងផាសទឹក

តាង Y (mol/L) ជាកំហាប់អ៊ីយ៉ូដក្នុងផាសសារធាតុរំលាយ $CCl_4$

យើងបាន $X + Y = 9 \times 10^{-5}$ M

ដោយ $\frac{\text{កំហាប់ } I_2 \text{ ក្នុងផាស } CCl_4}{\text{កំហាប់ } I_2 \text{ ក្នុងផាស } H_2O} = \frac{85}{1}$

$$\frac{\frac{Y}{0.025}}{\frac{X}{0.1}} = 85$$ នាំឲ្យ $Y = 21.25\ X$

យើងបាន $21.25\ X + X = 9 \times 10^{-5}$ M នាំឲ្យ $X = 4.04 \times 10^{-6}$ M

ដូចនេះកំហាប់អ៊ីយ៉ូដនៅសល់ក្នុងផាសទឹកគឺ $4.04 \times 10^{-6}$ M

ចំណាំ: ចូរព្យាយាមដោះស្រាយវិធីផ្សេងទៀតតាមសមត្ថភាពដែលអាចធ្វើបាន

៦. ក. សរសេរសមីការតាងប្រតិកម្មគីមីតាមលំដាប់លំដោយនៃប្រព្រឹត្តកម្មខាងលើ

$2\ Ag + 2\ H_2SO_4 \rightarrow Ag_2SO_4 + SO_2 + 2\ H_2O$

$Cu + 2\ H_2SO_4 \rightarrow CuSO_4 + SO_2 + 2\ H_2O$

$SO_2 + Br_2 + 2H_2O \rightarrow 2\ HBr + H_2SO_4$

$H_2SO_4 + Ba(NO_3)_2 \rightarrow BaSO_4 + 2HNO_3$

វិធីទី១៖ តាង X ជាម៉ាស Ag នោះ 1.12 – X ជាម៉ាស Cu

តាមសមីការខាងលើយើងបាន ½ n (Ag) + n (Cu) = n ($BaSO_4$)

$$\frac{1}{2}\frac{X}{108} + \frac{1.12 - X}{64} = \frac{1.864}{233} = 8 \times 10^{-3}$$

យើងបាន X = 0.864 g នោះ m (Cu) = 1.12 – 0.864 = 0.256 g

វិធីទី២៖ តាង X ជាចំនួនម៉ូល Ag និង Y ជាចំនួនម៉ូល Cu

តាមសមីការខាងលើយើងបាន ½ n (Ag) + n (Cu) = n ($BaSO_4$)

នោះ　$\frac{1}{2} X + Y = 8 \times 10^{-3}$　ឬ　$X + 2\ Y = 16 \times 10^{-3}$

$108\ X + 64\ Y = 1.12$

យើងបាន $X = 8 \times 10^{-3}$ mol និង $Y = 4 \times 10^{-3}$ mol

Let X is mass of Ag,
then, mass of Cu = 1.12 – X
or let X is mass of Cu,
then, mass of Ag = 1.12 – X

Let X is mole of Ag,
Y is mole of Cu
Then m (Ag) + m(Cu) = 1.12
108 X + 64 Y = 1.12

Let X is mole of Ag,
Then m (Ag) = 108 X
m (Cu) = 1.12 – 108 X
or let X is mole of Cu,
Then m (Cu) = 64 X
m (Ag) = 1.12 – 64 X

ដូចនេះ ម៉ាសប្រាក់ស្មើ 0.864 g និង ម៉ាសទង់ដែងស្មើ 0.256 g

**វិធីទី៣៖** តាង X ជាចំនួនម៉ូល Ag នោះម៉ាសម៉ាស Cu = 1.12 g – 108 X

តាមសមីការខាងលើយើងបាន $\frac{1}{2}$ n (Ag) + n (Cu) = n ($BaSO_4$)

$$\frac{1}{2}X + \frac{1.12 - 108X}{64} = \frac{1.864}{233} = 8 \times 10^{-3}$$

$$32X + 1.12 - 108X = (8 \times 10^{-3} \times 64) = 0.512$$

យើងបាន $X = 8 \times 10^{-3}$ mol

ដូចនេះ ម៉ាសប្រាក់ស្មើ $8 \times 10^{-3}$ mol x 108 g/mol = 0.864 g

ម៉ាសទង់ដែងស្មើ 1.12 g – 0.864 g = 0.256 g

**វិធីទី៤៖** តាង X ជាចំនួនម៉ូល Cu នោះម៉ាសម៉ាស Ag = 1.12 g – 64 X

តាមសមីការខាងលើយើងបាន $\frac{1}{2}$ n (Ag) + n (Cu) = n ($BaSO_4$)

$$\frac{1}{2}\,\frac{1.12 - 64X}{108} + X = \frac{1.864}{233} = 8 \times 10^{-3}$$

$$1.12 - 64X + 216X = (8 \times 10^{-3} \times 216) = 1.728$$

យើងបាន $X = 4 \times 10^{-3}$ mol

ដូចនេះ ម៉ាសទង់ដែងស្មើ $4 \times 10^{-3}$ mol x 64 g/mol = 0.256 g

